សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី23 ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ   អ៊ិន ប៊ុនហេង | លោក អ៊ឹង រដ្ឋា |
| បូរិន្ទ ឫទ្ធិរាជ | |


| | | |
|---|---|---|
| ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ | ឆ្នាំចូលរៀន | ២០១៨ |
| ជំនាន់ទី២២ | ឆ្នាំសរសេរសារណា | ២០២២ |

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហូរិន្ទ ឫទ្ធិរាជ** និង **អ៊ុន ប៊ុនហេង** ជានិស្សិតផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្តនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២ ជំនាន់ទី២២។

ខ្ញុំបាទទាំងពីរអ្នកសូមអរគុណដល់ឪពុកនិងម្តាយដែលបានមើលថែ និងចិញ្ចឹមបីបាច់ថែក្សា និងអប់រំតាំងពីតូចរហូតដល់ធំដឹងក្តី ដោយមិនគិតពីភាពនឿយហត់ឡើយ។ ពួកគាត់ទាំងពីរបានធ្វើការលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្តដើម្បីអោយពួកខ្ញុំបញ្ចប់ការសិក្សាបរិញ្ញាបត្រដោយជោគជ័យ ។ ការលះបង់នេះគឺមិនអាចកាត់ថ្លៃបានឡើយ។

ជាបន្តខ្ញុំបាទ **ហូរិន្ទ ឫទ្ធិរាជ** សូមថ្លែងអំណរអរគុណដល់ ឯកឧត្តមសេង ទៀង ដែលបានផ្តល់ អាហារូបករណ៍ដល់ខ្ញុំបាទក្នុងរយៈពេល០៤ឆ្នាំ រហូតដល់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រជំនាញ នីតិសាស្ត្រ បានដោយជោគជ័យ។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណចំពោះ **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោកលោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់នូវដំបូន្មានល្អៗយ៉ាងពិតប្រាកដ សម្រាប់ជាយានបំភ្លឺផ្លូវដល់ជីវិតរបស់យើងខ្ញុំនៅក្នុងថ្នាក់បរិញ្ញាបត្រមួយនេះ។

ជាពិសេសយើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **អ៊ឹង រដ្ឋា** ដែលជា សាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឱ្យមានដំណើរការនៃការតាក់តែងសារណានេះឡើងមកប្រកបដោយភាពជោគជ័យ។ ជាពិសេសលោកបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ តម្រង់ទិស ផ្តល់ឯកសារ និងអនុសាសន៍ល្អៗដល់រូបខ្ញុំទាំងពីរ ព្រមទាំងជួយកែលម្អនូវចំណុចខ្វះខាតទាំងឡាយរបស់ពួកខ្ញុំដើម្បីធ្វើយ៉ាងណាឱ្យសារណារបស់យើងខ្ញុំទទួលបាននូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធិពរជ័យបវរជូនដល់ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតតំណាងរាស្ត្រ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់**សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

ការសិក្សាអស់រយៈពេល ៤ឆ្នាំនេះ បានអោយពួកខ្ញុំទាំងពីរអ្នកឈានមកដល់នូវការធ្វើកិច្ចការស្រាវជ្រាវក្រោមប្រធានបទ **ការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរ** ដែលមានសាស្ត្រាចារ្យដឹកនាំលោក អ៊ឹង រដ្ឋា ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សាក្នុងថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

ការសម្រេចចិត្តជ្រើសរើសនូវប្រធានបទខាងលើនេះ មកសិក្សាស្រាវជ្រាវជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ គឺដោយសារតែយើងខ្ញុំទាំងពីរនាក់យល់ឃើញថា វាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ ដែលអ្នកអនុវត្តនីតិវិធីនៅតាមសាលាជម្រះក្តីទាំងអស់ត្រូវតែគោរពឱ្យបានត្រឹមត្រូវ។ម្យ៉ាងទៀតការស្រាវជ្រាវនេះបានទទួលការយល់ព្រម និងមានការឯកភាព និងលើកទឹកចិត្តពីលោកគ្រូសាស្ត្រាចារ្យដឹកនាំសរសេរសារណាក្នុងការជម្រុញឱ្យកិច្ចការនេះបានសម្រេចចេញជាលទ្ធផល។

ការស្រាវជ្រាវលើប្រធានបទមួយនេះ ត្រូវបានចាប់ផ្តើមដោយការយកឯកសារច្បាប់ ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ លិខិតណែនាំរបស់ក្រសួងយុត្តិធម៌ ព្រមទាំងឯកសារ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ទាំងលិខិតបទដ្ឋានជាតិ និងលិខិតបទដ្ឋានអន្តរជាតិ និងតាមរយៈការសាកសួរយោបល់ផ្ទាល់ជាមួយចៅក្រមមេធាវី និងក្រឡាបញ្ជី ដើម្បីយកមកបូកបញ្ចូលឱ្យចេញជាឯកសារស្រាវជ្រាវមួយនេះ ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការអនុវត្តនៅក្នុងការអនុវត្តនីតិវិធីនៃប្រធានបទមួយនេះ។

ក្រោយពីការស្រាវជ្រាវបានបញ្ចប់ យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងក្លាយជាអត្ថបទដែលមានសារៈប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្នែកនីតិសាស្ត្រទាំងអស់ ជាពិសេសអ្នកដែលមានតួនាទីអនុវត្តនីតិវិធីនៅតាមសាលាជម្រះក្តីនានា។ ជាងនេះទៅទៀត វានឹងក្លាយជាឯកសារមួយដែលបានចូលរួមចំណែកក្នុងការផ្សព្វផ្សាយច្បាប់ និងការស្រាវជ្រាវផ្នែកនីតិវិធីព្រហ្មទណ្ឌឱ្យកាន់តែសម្បូរបែបផងដែរ។

ទោះបីជាសារណាមួយនេះត្រូវបានខិតខំធ្វើការស្រាវជ្រាវ និងធ្វើការត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយយើងខ្ញុំទាំងពីរនាក់យ៉ាងណាក៏ដោយ ក៏សារណាបញ្ចប់ការសិក្សាមួយនេះនៅមានភាពខ្វះចន្លោះមួយចំនួនផងដែរ ដូច្នេះយើងខ្ញុំទាំងពីរនាក់រងចាំទទួលនូវការរិះគន់ពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិតទាំងអស់ ដើម្បីកែលម្អសារណាមួយនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**......1

១. លំនាំបញ្ហានៃការស្រាវជ្រាវ......1

២. ចំណោទបញ្ហានៃការដោះស្រាយ......1

៣. គោលបំណងនៃការស្រាវជ្រាវ......2

៤. ដែនកំណត់នៃការស្រាវជ្រាវ......2

៥. សារៈសំខាន់នៃការស្រាវជ្រាវ......2

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ......2

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ......3

## ជំពូកទី១

## សញ្ញាណទូទៅការឃុំខ្លួនបណ្តោះអាសន្ន

**១.១. ការឃុំខ្លួនបណ្តោះអាសន្ន**......4

**១.១.១. អត្ថន័យនៃការឃុំខ្លួនបណ្តោះអាសន្ន**......4

**១.១.២. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន**......4

**១.១.៣. សិទ្ធិសេរីភាពរបស់ជនត្រូវចោទ**......5

**១.១.៤. សិទ្ធិរបស់ជនត្រូវចោទ**......5

១.១.៤.១. សិទ្ធិមានអ្នកតំណាងដែរជាមេធាវី......5

១.១.៤.២. សិទ្ធិស្នើសុំអោយដោះលែងអោយនៅក្រៅឃុំរបស់ជនត្រូវចោទ......6

១.១.៤.៣. សិទ្ធិស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ......6

១.១.៤.៤. សិទ្ធិស្នើសុំបិទសំណុំរឿង......7

១.១.៤.៥. សិទ្ធិប្តឹងជិតចិត្ត......7

១.១.៤.៦. សិទ្ធិនៃភាពចាំបាច់ក្នុងការធ្វើកោសលវិច័យ......8

១.១.៤.៧. សិទ្ធិទទួលបានដំណឹងអំពីដីកាដំណោះស្រាយ ........ 9
១.១.៤.៨. សិទ្ធិទទួលបានដំណឹងពីការបិទបញ្ចប់សំណុំរឿង ........ 10
**១.២. គោលការណ៍ទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ 11
**១.២.១. លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ 11
១.២.១.១. លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់ ........ 11
១.២.១.២. លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ ........ 11
១.២.១.៣. លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ ........ 12
**១.២.២. មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ 12
១.២.២.១. មូលហេតុទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន ........ 12
១.២.២.២. មូលហេតុពិសេសនៃការឃុំខ្លួនបណ្ដោះអាសន្ន ........ 16
**១.២.៣. អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ 16

**ជំពូកទី២**

**ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន**

**១.១. ថិរវេលាទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ 17
**១.១.១. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះនីតិជន** ........ 17
១.១.១.១. ករណីបទឧក្រិដ្ឋ ........ 17
១.១.១.២. ករណីបទមជ្ឈិម ........ 17
**១.១.២. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជន** ........ 17
១.១.២.១. ករណីបទឧក្រិដ្ឋ ........ 18
១.១.២.២. ករណីបទមជ្ឈិម ........ 18
**១.២. ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ 18
**១.៣. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ** ........ 19
**១.៤. ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........ 19
**១.៥. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះមូលហេតុពិសេស** ........ 19

១.៦. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្រោយចេញដីកាដំណោះស្រាយ ... 19

## ជំពូកទី៣

## នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន

១.១. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ... 21
១.២. កិច្ចបង្ហាញខ្លួនលើកដំបូង ... 21
១.៣. ការពិភាក្សាដេញដោលចំពោះមុខ ... 23
១.៤. ការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ... 23
១.៥. ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន ... 23

## ជំពូកទី៤

## ការមិនឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ

១.១. ការមិនឃុំខ្លួនបណ្តោះអាសន្ន ... 25
១.១.១. ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ... 25
១.១.២. ការសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ... 25
១.១.២.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ ... 26
១.១.២.២. ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា ... 26
១.១.២.៣. ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ជនត្រូវចោទ ... 26
១.២. ការត្រួតពិនិត្យតាមផ្លូវតុលាការ ... 26
១.២.១. ភាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ... 27
១.២.២. ការឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីបំពានភាតព្វកិច្ចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ... 28
សេចក្តីសន្និដ្ឋាន ... 29
អនុសាសន៍ ... 31
ឯកសារយោង

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ស្ថាប័នតុលាការ គឺជាស្ថាប័នមួយដែលមានលក្ខណៈឯករាជ្យ ហើយមានតួនាទីយ៉ាងសំខាន់នៅក្នុងការស្វែងរកយុត្តិធម៌នៅក្នុងសង្គម ក៏ដូចជាស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលរស់ក្នុងសង្គមនោះ ដើម្បីធ្វើការទប់ស្កាត់នូវរាល់អំពើបំពានដែលជាបទល្មើសនានា ហើយកើតឡើងជារឿយៗនៅក្នុងសង្គម។

បច្ចុប្បន្ននេះ បើយើងធ្វើការសង្កេតមើលទៅក្នុងសង្គម យើងឃើញថាបទល្មើសព្រហ្មទណ្ឌបាននឹងកំពុងកើតមានជាច្រើន ដែលវាតម្រូវឱ្យតុលាការព្រហ្មទណ្ឌ មានតួនាទីក្នុងការចូលរួមដោះស្រាយនូវបញ្ហានេះក្នុងគោលបំណងដើម្បីទប់ស្កាត់ ក៏ដូចជាកាត់បន្ថយបទល្មើសទាំងនោះ កុំឱ្យមានការរីករាលដាលក្នុងសង្គមកាន់តែធ្ងន់ធ្ងរឡើងជាងនេះទៀត។ នៅក្នុងដំណើរការនៃការដោះស្រាយនេះ តុលាការព្រហ្មទណ្ឌត្រូវតែអនុវត្តឱ្យបានច្បាស់លាស់ទៅតាមវិធានដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានមួយ ដែលកំណត់អំពីដំណើរការនៃការជម្រះក្ដីក្នុងរឿងក្ដីព្រហ្មទណ្ឌដែលបានបែងចែងជាដំណាក់កាលចាប់តាំងពីពេលស៊ើបអង្កេត ចោទប្រកាន់ បើកការស៊ើបសួរ ការជំនុំជម្រះក្ដី រហូតដល់ការអនុវត្តទណ្ឌកម្ម។

នៅក្នុងនោះដែរ ដំណាក់កាលនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការស្វែងរកការពិត ដោយចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក[1]។ មួយវិញទៀតចៅក្រមស៊ើបសួរក៏មានសិទ្ធិអំណាចមួយចំនួនដែលបានផ្ដល់ឱ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ ដូចជាសិទ្ធិអំណាចនៃការអនុវត្តវិធានការនិរន្តរាយ ដែលជាវិធានមួយដែលចៅក្រមស៊ើបសួរត្រូវការប្រើប្រាស់ជាចាំបាច់ ក្នុងការសម្រួលឱ្យមានប្រសិទ្ធភាពនៃការអនុវត្តខ្ពស់។ ជាក់ស្ដែងដូចជាការឃុំខ្លួនបណ្ដោះអាសន្ន ដែលវាគឺជាវិធានមួយនៅក្នុងចំណោមវិធានការនិរន្តរាយ ហើយវាក៏ជាការផ្ដល់នូវសិទ្ធិអំណាចឱ្យចៅក្រមស៊ើបសួរអាចដកហូតនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទ ក្នុងការធានានូវកិច្ចនីតិវិធីផងដែរ។ **ការឃុំខ្លួនបណ្ដោះអាសន្ន** គឺជាវិធានមួយដែលចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទដែលមានវត្តមាន និងអត្តសញ្ញាណដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ទន្ទឹមនឹងការលើកឡើងខាងលើ មានបញ្ហា ក៏ដូចជាចម្ងល់មួយចំនួនត្រូវបានចោទជាសំនួរពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរដូចជា **តើការឃុំខ្លួនបណ្ដោះអាសន្ននេះធ្វើឡើង**

[1] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧,, មាត្រា ១២៧ កថាខណ្ឌទី ២

**ត្រូវគោរពតាមគោលការណ៍អ្វីខ្លះ? តើថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានកំណត់យ៉ាងដូចម្តេចខ្លះ? នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នមានលំហូរនីតិវិធីយ៉ាងដូចម្តេច?**

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **ការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរ** នេះក្នុងគោលបំណង ៖

-យល់ច្បាស់នូវនីតិវិធីដើម្បីសម្រេចឃុំខ្លួនបុគ្គលណាម្នាក់ជាបណ្តោះអាសន្ន។

-ចូលរួមផ្សព្វផ្សាយ និងជំរុញការស្រាវជ្រាវផ្នែកច្បាប់ ជាពិសេសចែករំលែកនូវការស្រាវជ្រាវផ្នែកនីតិវិធីឱ្យកាន់តែសម្បូរបែប។

-យល់ដឹងពីការគោរព និងធានានូវប្រសិទ្ធភាពនៃការអនុវត្តទាក់ទងនឹងនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ទាក់ទងនឹងការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាផ្នែកបរិញ្ញាបត្រនីតិសាស្ត្រនេះ យើងខ្ញុំបានយកចិត្តទុកដាក់ក្នុងការចងក្រងនូវចំណុចនានា ដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ពោលគឺយើងខ្ញុំសូមសិក្សាទៅលើ **ការឃុំខ្លួនបណ្តោះអាសន្ន ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្តោះអាសន្នចំពោះនីតិជន និងអនីតិជន តែប៉ុណ្ណោះ។**

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះអាចធ្វើឱ្យពួកយើងខ្ញុំយល់ដឹងកាន់តែច្បាស់អំពីបញ្ហាប្រឈមទាក់ទងទៅនឹងប្រធានបទមួយនេះ ក៏ដូចជាទទួលបានចំណេះដឹងមួយកាន់តែច្បាស់ទាក់ទងទៅនឹងនីតិវិធីព្រហ្មទណ្ឌ ដែលពួកយើងខ្ញុំត្រូវយកទៅអនុវត្តនៅថ្ងៃអនាគត ដែលចំណេះទាំងនេះទទួលបានពីសាស្ត្រាចារ្យណែនាំ ក៏ដូចជារៀមច្បងជំនាន់មុនៗ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីសម្រេចបាននូវការស្រាវជ្រាវនូវប្រធានបទមួយនេះ យើងបានធ្វើការសិក្សានូវឯកសារពាក់ព័ន្ធនានា ដែលមានលក្ខណៈជាទ្រឹស្តីគតិយុត្តជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ និងបានទទួលនូវយោបល់ល្អៗទាក់ទងនឹងប្រធានបទពីចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី ក៏ដូចជាសាស្ត្រាចារ្យជាដើម។ ចំពោះប្រភពឯកសារដែលជាទ្រឹស្តីមានជាប្រភេទលិខិតបទដ្ឋានគតិយុត្ត ដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ប្រកាស សេចក្តីណែនាំ របស់ក្រសួងយុត្តិធម៌ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន និងសៀវភៅសន្និសិទ្ធស្តីពីការ

ណែនាំដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ព្រមទាំងឯកសារគតិយុត្តផ្សេងៗទៀត។ ក្នុងនោះ ក៏មានការចូលរួមចំណែកផ្តល់នូវដំបូន្មានល្អៗពីលោកគ្រូសាស្ត្រចារ្យណែនាំទៅលើប្រធានបទនេះផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាអំពីប្រធានបទទាក់ទងនឹង **ការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរ** យើងខ្ញុំសូមធ្វើការបកស្រាយជា ៤ (បួន) ជំពូកសំខាន់ៗ ដែលរួមមាន៖ **ជំពូកទី១ សញ្ញាណទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន ជំពូកទី២ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ជំពូកទី៣ សិក្សាអំពីនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន** និង **ជំពូកទី៤ ការមិនឃុំខ្លួនបណ្តោះអាសន្ន និង ការត្រួតពិនិត្យតាមផ្លូវតុលាការ។**

# ជំពូកទី១

# សញ្ញាណទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំឡើងទៅ។

## ១.១. ការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់៖ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំអោយកើតជាថ្មី ដើម្បីរារាំងកុំអោយមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះឬដើម្បីរារាំងកុំអោយមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនិងអ្នកសមគំនិត ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ដើម្បីការពារសន្តិសុខអោយជនត្រូវចោទ ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំអោយមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស[2]។

ដើម្បីជួយសម្រួលដល់ការដំណើរការនីតិវិធីរបស់តុលាការ ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់សិទ្ធិអំណាចទៅអោយចៅក្រមស៊ើបសួរអាចប្រើប្រាស់នូវវិធានការចំនួនពីរ គឺការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

### ១.១.១. អត្ថន័យនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាការដកហូតសិទ្ធិសេរីភាពបុគ្គលណាម្នាក់ ដោយបុគ្គលម្នាក់នោះត្រូវបានជាប់ឃុំឃាំងនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ក្រោយពីជននោះត្រូវគេសង្ស័យថាបានប្រព្រឹត្តបទល្មើស ហើយត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅពេលដែលលក្ខខណ្ឌនៃបុគ្គលនោះ បានបំពេញទៅតាមការកំណត់របស់ច្បាប់។

### ១.១.២. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនជាបណ្តោះអាសន្ននេះគឺត្រូវបានធ្វើឡើងបន្ទាប់ពីបើកការស៊ើបសួរបឋមរួចហើយ ហើយយល់ឃើញថា ជនត្រូវចោទនោះមានតម្រុយនៃពិរុទ្ធភាពនោះចៅក្រមស៊ើបសួរគាត់ជូនដំណឹងទៅព្រះរាជអាជ្ញា និង

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៥

មេធាវីអំពីការឃុំខ្លួនជាបណ្ដោះអាសន្នទៅលើជនត្រូវចោទនោះនិងដើម្បីរៀបចំបញ្ជូនសំណុំរឿងទៅតុលាការជំនុំជម្រះ។

**១.១.៣. សិទ្ធិសេរីភាពរបស់ជនត្រូវចោទ**

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកទី៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ[3]។ គ្មានជនណាម្នាក់ត្រូវបានគេចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនតាមអំពើចិត្តនោះទេ។ គ្មានជនណាម្នាក់ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់[4]។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់[5]។

ការឃុំខ្លួនអាចត្រូវធ្វើបានលុះត្រាតែប្រព្រឹត្តទៅបានក្នុងករណីពិសេសតែប៉ុណ្ណោះ មានន័យថាចៅក្រមស៊ើបសួរមានសិទ្ធិឃុំខ្លួនបណ្ដោះអាសន្នដោយផ្ដល់ដោយច្បាប់ តែត្រូវប្រព្រឹត្តឡើងក្នុងលក្ខខ័ណ្ឌប្រកាន់ខ្ជាប់ថាជនត្រូវចោទត្រូវបានសេរីភាព។

ចៅក្រមស៊ើបសួរត្រូវបានផ្ដល់សិទ្ធិអំណាចក្នុងការសម្រេចឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទយ៉ាងណាក៏ដោយ ប៉ុន្តែចៅក្រមស៊ើបសួរត្រូវមានកាតព្វកិច្ចក្នុងការអនុវត្តនីតិវិធីឬនូវវិធានដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយផ្អែកលើគោលការណ៍សេរីភាពរបស់បុគ្គលម្នាក់ៗ ក្នុងការចៀសវាងនូវការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលដទៃ។

**១.១.៤. សិទ្ធិរបស់ជនត្រូវចោទ**

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌគ្រប់ដំណាក់កាលនៃនីតិវិធី ជនត្រូវចោទអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការប្រាស្រ័យទាក់ទងមេធាវីរបស់ខ្លួនដោយសេរីនៅពេលដែលខ្លួនកំពុងជាប់ឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដោយពុំមាននរណាម្នាក់រារាំងបាននោះទេ ហើយនេះមិនមែនជាសិទ្ធិតែមួយគត់ដែលជនត្រូវចោទទទួលបាននោះទេ ច្បាប់បានផ្ដល់សិទ្ធិផ្សេងៗផងដែរដូចជា៖

**១.១.៤.១. សិទ្ធិមានអ្នកតំណាងដែរជាមេធាវី**

មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី[6]។ ជនត្រូវចោទដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន មានសិទ្ធិជ្រើសរើសមេធាវីក្នុងករណីមិនទាន់បានជ្រើសរើស

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៣
[4] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៩
[5] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា ៣៨ កថាខណ្ឌទី២
[6] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៤៣ កថាខណ្ឌទី៤

ឬ អាចស្នើសុំមេធាវីក្នុងករណីខ្លួនពុំមានលទ្ធភាព ឬ មេធាវីត្រូវបានចាត់តាំងដោយតុលាការ ហើយជនត្រូវចោទក៏អាចធ្វើការផ្លាស់ប្ដូរមេធាវីបានផងដែរ។

ក្នុងករណីដែរជនត្រូវចោទជាជនក្រីក្រហើយគ្មានលទ្ធភាពក្នុងការជ្រើសរើសមេធាវី ក៏អាចធ្វើការស្នើសុំបានដែរ ការស្នើរនេះទៀតសោតគឺត្រូវធ្វើឡើងដោយការសុំទៅកាន់គណៈមេធាវីដែលទទួលបន្ទុកការពារជនក្រីក្រ ឬមួយតាមបណ្ដាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗដែលមានផ្ដល់ជំនួយផ្នែកច្បាប់ជាពិសេសសេវាមេធាវីដោយឥតគិតថ្លៃ។ ក្នុងរយៈពេលដែរទទួលដំណឹងអំពីសិទ្ធិជ្រើសរើសមេធាវី និងសិទ្ធិស្នើសុំមេធាវី តុលាការអាចចាត់តាំងមេធាវីបានផងដែរ ចំពោះជនត្រូវចោទដែលជាអនីតិជនដែលត្រូវមានមេធាវីអមជានិច្ច។

### ១.១.៤.២. សិទ្ធិស្នើសុំអោយដោះលែងអោយនៅក្រៅឃុំរបស់ជនត្រូវចោទ

ជនត្រូវចោទអាចមានសិទ្ធិគ្រប់គ្រាន់ក្នុងការដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំគ្រប់ពេលវេលា[7]។ ក្នុងការស្នើសុំនេះត្រូវផ្ដល់ជូនចៅក្រមស៊ើបសួរ បន្ទាប់ពីចៅក្រមស៊ើបសួរទទួលបានការស្នើរសុំនេះរួច ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត រយៈពេលនៃការបញ្ជូននេះមិនមានការកំណត់ច្បាស់លាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ ប៉ុន្តែការសម្រេចរបស់ចៅក្រមស៊ើបសួរមានរយៈពេល៥ថ្ងៃបន្ទាប់ពីបានបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

ក្នុងករណីដែរចៅក្រមស៊ើបសួរធ្វើការបដិសេធពាក្យសុំពីមុន ជនត្រូវចោទអាចមានសិទ្ធិក្នុងការដាក់ពាក្យសុំនៅក្រៅឃុំសារជាថ្មីម្ដងទៀតទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល១ខែបន្ទាប់ពីការបដិសេធនោះ។ ក្រោយពីការទទួលពាក្យនោះ ចៅក្រមស៊ើបសួរឬសភាស៊ើបសួរ ត្រូវធ្វើការសម្រេចលើពាក្យនេះក្នុងរយៈពេល៥ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្ដឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ១.១.៤.៣. សិទ្ធិស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

ទោះបីជាជនជាប់ចោទកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នក៏ដោយ ក៏បុគ្គលនោះនៅមានសិទ្ធិក្នុងការស្នើសុំអោយចៅក្រមស៊ើបសួរបញ្ជាក់ពីនត្ថិភាពនៃបទល្មើស ដែលអយ្យការបានចោទប្រកាន់ខ្លួនបានដែរ។ នៅគ្រប់ពេលនៃការស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើការបំពេញកិច្ចមួយចំនួនដូចជា៖ ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។

ការស្នើសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដើម្បីបញ្ជាក់ពីភាពប្រាកដច្បាស់លាស់ និងត្រូវសរសេរពីសំអាងហេតុឱ្យបានត្រឹមត្រូវ។ ក្នុងករណីដែរចៅក្រមស៊ើបសួរមិនព្រមធ្វើតាមការស្នើរសុំរបស់ជនជាប់ចោទ

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៧

នោះទេ ចៅក្រមស៊ើបសួរដែរបដិសេធនោះត្រូវចេញដីកាបដិសេធនៅក្នុងថេរវេលា១ (មួយ)ខែ បន្ទាប់ពីពេលដែលទទួលបានពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ក្នុងករណីបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងថិរវេលា១(មួយ)ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[8]។

ដីការដែលមិនព្រមដោះលែងអោយនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។

### ១.១.៤.៤. សិទ្ធិស្នើសុំបិទសំណុំរឿង

នៅពេលផុតថិរវេលា ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចោទប្រកាន់ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ[9]។ នៅក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលពាក្យនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្តឹងទៅប្រធានសភាស៊ើបសួរដែលធ្វើអធិបញ្ញាដល់ចៅក្រមស៊ើបសួរអោយសម្រេច។ ជនត្រូវចោទត្រូវបានផ្តល់នូវសិទ្ធិនេះដោយក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីជៀសវាងនូវកំហុសឬការខ្ជីខ្ជាដោយកើតឡើងក្នុងប្រការណាមួយដោយអចេតនាពីចៅក្រមស៊ើបសួរ។

លុះផុតថិរវេលា១ ឆ្នាំ គិតពីថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំអោយចៅក្រមស៊ើបសួរបិទការស៊ើបសួរ។ ក្នុងរយៈពេល ១ ខែគិតពីការទទួលពាក្យប្តឹងសុំ ចៅក្រមស៊ើបសួរត្រូវតែសម្រេច។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលនេះទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលធ្វើអធិបញ្ញាចៅក្រមស៊ើបសួរសម្រេច។

អំណាចដែលទទួលស្គាល់អំពីការប្តឹងសុំបិទសំណុំរឿងដល់ជនត្រូវចោទនេះ អាចត្រូវបានប្រើប្រាស់ដោយមេធាវីរបស់ជនត្រូវចោទបាន។

### ១.១.៤.៥. សិទ្ធិប្តឹងជំទាស់

ការប្តឹងជិតចិត្ត គឺជាសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងបដិសេធវត្តមានរបស់ចៅក្រមអាសនៈដោយពុំអនុញ្ញាតឱ្យចៅក្រមទទួលបន្ទុករឿងក្តីណាមួយ។ ចៅក្រមនៅទីនេះ គឺសំដៅទៅលើចៅក្រមអាសនៈ អាចជាចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះ។

បណ្តឹងជិតចិត្ត អាចត្រូវបានទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈតែប៉ុណ្ណោះ[10]។ ចំពោះមូលហេតុនៃការប្តឹងជិតចិត្តត្រូវបានច្បាប់កំណត់យ៉ាងជាក់លាក់នៅក្នុងមាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូចជា៖

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៣៣

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៨៦

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៥៥៦ កថាខណ្ឌទី១

- កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយនៅក្នុងរឿងក្តី
- កាលណាចៅក្រមជាញាតិលោហិតដល់ថ្នាក់ទី៦ ឬ ញាតិពន្ធដល់ថ្នាក់ទី៣ ឬ អតីតញាតិពន្ធដល់ថ្នាក់ទី៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬ កំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើសាក្សី ឬ អ្នកជំនាញក្នុងរឿងក្តី
- កាលណាចៅក្រមជា ឬ ធ្លាប់ជាអ្នកតំណាង ឬ អ្នកជំនួយឱ្យភាគីចំពោះរឿងក្តី ឬ
- កាលណាចៅក្រមបានចូលរួមក្នុងនាមជាមជ្ឈត្តករក្នុងរឿងក្តី ឬ បានចូលរួមក្នុងការសម្រេចសេចក្តីនៅសាល

ដំបូងដែលបានប្តឹងឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី។

អំពីមូលហេតុនៃការប្តឹងជិតចិត្ត គឺក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់សម្រាប់គូភាគី អាចប្តឹងជិតចិត្តបាន។ ក្រៅពីការប្តឹងជិតចិត្តច្បាប់ក៏ទុកសិទ្ធិដល់ចៅក្រមក្នុងការដកខ្លួនពីរឿងក្តីផងដែរ។ ចៅក្រមអាចមានមូលហេតុត្រឹមត្រូវមិនព្រមចូលរួមក្នុងការស៊ើបសួរ ឬ ជំនុំជម្រះរឿងក្តីណាមួយនោះអាចសុំឱ្យគេជំនួសបាន[11]។ ក្នុងការស្នើសុំនេះចៅក្រមត្រូវធ្វើពាក្យសុំជូនទៅប្រធានតុលាការរបស់ខ្លួន បន្ទាប់ពីទទួលបានពាក្យនេះប្រធានតុលាការធ្វើការពិនិត្យថាតើមូលហេតុនេះត្រឹមត្រូវនោះទេ។ ប្រសិនបើយល់ឃើញថាត្រឹមត្រូវ ប្រធានតុលាការចាត់ចែងចៅក្រមផ្សេងមកជំនួសចៅក្រមនេះ ការសម្រេចនេះដែរមិនអាចតវ៉ាបានឡើយ។

ជនត្រូវចោទដែលចង់ប្តឹងជិតចិត្តចៅក្រមអាសនៈណាមួយត្រូវជូនដំណឹងពាក្យប្តឹងតាំងពីពេលដែលខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជិតចិត្ត បើពុំដូច្នេះទេមិនអាចទទួលបានឡើយ។ ប៉ុន្តែនៅក្រោយពេលបិទការពិភាក្សាដេញដោលពាក្យប្តឹងជិតចិត្តចៅក្រមមិនអាចធ្វើបានឡើយ[12]។

### ១.១.៤.៦. សិទ្ធិនៃភាពចាំបាច់ក្នុងការធ្វើកោសលវិច័យ

ចៅក្រមស៊ើបសួរអាចបង្គាប់អោយធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់របស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង[13]។

---

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៥៥៥

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៥៥៧

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៦២

ក្នុងករណីដែលចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។

ក្នុងការស្នើសុំនោះ ប្រសិនជាជាយល់ឃើញថាមានការការចាំបាច់ដើម្បីបញ្ជាក់ឬមានប្រយោជន៍ក្នុងការបង្ហាញអោយឃើញការពិត ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក[14]។ ចៅក្រមស៊ើបសួរនឹងសម្រេចដោយចេញដីកាចាត់តាំងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ឬ ចាត់តាំងអ្នកជំនាញដែលមិនមានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិឱ្យធ្វើកោសលវិច័យ។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យស្នើសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ០១(មួយ)ខែ ចំពោះការស្នើសុំដោយជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែការស្នើសុំធ្វើដោយព្រះរាជអាជ្ញា កោសលវិច័យត្រូវដាក់បញ្ចូលនៅក្នុងសំណុំរឿង។ ចៅក្រមស៊ើបសួរត្រូវកោះហៅជនត្រូវចោទ និងមេធាវី ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃការធ្វើកោសលវិច័យ។

ចៅក្រមស៊ើបសួរកំណត់ពេលមិនអាចតិចជាង១០ថ្ងៃ ដែលអនុញ្ញាតអោយព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ[15]។ ក្នុងរយៈពេលនេះសំណុំរឿងដែលរួមមានរបាយការណ៍កោសវិច័យ អាចត្រូវបានពិនិត្យមើលដោយមេធាវី។ ចំពោះទម្រង់នៃពាក្យស្នើសុំធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យត្រូវធ្វើឡើងដោយមានសំអាងហេតុ និងជាលាយលក្ខណ៍អក្សរ។ កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំកោសលវិច័យ ឬ ប្រតិកោសលវិច័យ ចៅក្រមស៊ើបសួរត្រូវសម្រេចដោយដីកាមានសំអាងហេតុ។ ប្រសិនបើការស្នើសុំធ្វើឡើងដោយជនត្រូវចោទ ដីកាត្រូវសម្រេចក្នុងរយៈពេល ០១(មួយ)ខែ និងត្រូវជូនដំណឹងដល់ជនត្រូវចោទផងដែរ។ គ្រប់ពាក្យសុំធ្វើកោលសវិច័យបន្ថែម ឬ ប្រតិកោសលវិច័យធ្វើឡើងក្រោយផុតរយៈពេលកំណត់ដោយចៅក្រមស៊ើបសួរត្រូវដាក់ចូលនៅក្នុងសំណុំរឿង។ ប៉ុន្តែប្រសិនជាចៅក្រមស៊ើបសួរមិនព្រមសម្រេចក្នុងរយៈពេលខាងលើទេ ជនត្រូវចោទអាចធ្វើការប្ដឹងដោយផ្ទាល់ទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

### ១.១.៤.៧. សិទ្ធិទទួលបានដំណឹងអំពីដីកាដំណោះស្រាយ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី។ បន្ទាប់ពីការជូនដំណឹងអំពីការបិទការស៊ើបសួរ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួដែរថាការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានស្ពាពជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ នៅក្នុងសេចក្តីសន្និដ្ឋានស្ពាពនេះ ព្រះរាជ

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១២៧

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៧០ កថាខណ្ឌទី៥

អាជ្ញាប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់[16]។

ក្រោយពីធ្វើដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកានោះដោយភ្ជាប់ជាមួយសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរ។ បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានស្ថាពររួចហើយ ចៅក្រមស៊ើបសួរត្រូវធ្វើដីកាដំណោះស្រាយ ដីកានេះអាចជាដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនឱ្យសម្រេចការរឹបអូស[17]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការធ្វើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ[18]។ ចំពោះដីកាដំណោះស្រាយនោះគឺចាំបាច់ត្រូវជូនដំណឹងទៅកាន់ជនត្រូវចោទ ដែលត្រង់នេះបញ្ជាក់ថាជនត្រូវចោទក៏មានសិទ្ធិក្នុងការទទួលបាននូវដំណឹងអំពីដីកាដំណោះស្រាយផងដែរ។

### ១.១.៤.៨. សិទ្ធិទទួលបានដំណឹងពីការបិទបញ្ចប់សំណុំរឿង

កាលណាចៅក្រមស៊ើបសួរ យល់ឃើញថាការស៊ើបសួរបានបញ្ចប់ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីប្រសិនបើមាន[19]។ នៅក្នុងពេលដែលមានការជូនដំណឹងអំពីការបិទការស៊ើបសួរនេះ ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការស្នើរសុំអោយចៅក្រមស៊ើបសួរធ្វើការបំពេញកិច្ចណាមួយបាន។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាមានការចាំបាច់ត្រូវធ្វើការស៊ើបសួរថ្មីនេះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែជនត្រូវចោទវិញ តើគាត់អាចមានសិទ្ធិស្នើសុំអោយបំពេញកិច្ចដូចព្រះរាជអាជ្ញាដែលមានចែងនៅក្នុងមាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានដែរឬទេ?

អំពីបញ្ហានេះមានការបកស្រាយផ្សេងៗពីគ្នាពីសំណាក់សិស្សនិស្សិត សាស្ត្រាចារ្យ ឬពីសំណាក់អ្នកអនុវត្តច្បាប់។មានមតិពីរនៃការយល់អំពីបញ្ហានេះដោយៈ

មតិទីមួយៈ យល់ឃើញថាជនត្រូវចោទមានសិទ្ធិស្នើអោយចៅក្រមស៊ើបសួរបំពេញកិច្ចដូចដែលមានចែងក្នុងមាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន។

មតិទីពីរៈ បកស្រាយថានៅពេលដែលចៅក្រមស៊ើបសួរជូនដំណឹងដល់ជនត្រូវចោទអំពូការបិទការស៊ើបសួរហើយ ជនត្រូវចោទពុំអាចស្នើសុំអោយបំពេញកិច្ចដូចមានចែងនៅក្នុងមាត្រា ១៣៣ បានឡើយ មាន

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៤៦ កថាខណ្ឌទី៥

[17] ច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា៣៨២, ០៩ មិថុនា ២០១៣, មាត្រា ២៤៧ ថ្មី

[18] ច្បាប់ស្តីពីវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា៣៨២, ០៩ មិថុនា ២០១៣, មាត្រា ២៤៧ ថ្មី

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៤៦ ថាខណ្ឌទី១

ន័យថាបើគាត់ចង់ស្នើសុំអោយបំពេញកិច្ចដូចមានចែងក្នុងមាត្រានេះគាត់ត្រូវស្នើសុំអោយបានមុនការជូនដំណឹងអំពីការបិទការស៊ើបសួរ។

## ១.២. គោលការណ៍ទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន

ចំពោះគោលការណ៍ទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន គឺគេផ្អែកទៅលើលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន និងអានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន។

### ១.២.១. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន

មុននឹងចៅក្រមស៊ើបសួរសម្រេចថាឃុំខ្លួនបណ្តោះអាសន្នទៅលើបុគ្គលណាមួយ ចៅក្រមស៊ើបសួរត្រូវពិចារណាឱ្យបានច្បាស់លាស់ទៅលើលក្ខខណ្ឌបី ដែលរួមមាន លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់ លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ និងលក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ។

#### ១.២.១.១. លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់

នៅក្នុងករណីដែលមានការចោទប្រកាន់ពីបទលហុ ការធ្វើការឃុំខ្លួនបណ្តោះអាសន្នមិនអាចធ្វើបានឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ផន្ទន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ[20]។ ចំពោះការចោទប្រកាន់នេះ គឺធ្វើឡើងតាមរយៈអង្គការអយ្យការ ដែលអាចធ្វើការចោទប្រកាន់បានចំនួនបីមានដូចជា ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[21]។

ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬ មិនធ្វើក៏បាន[22]។ ក្នុងបទមជ្ឈិមមានពីរប្រភេទ ដូចជាបទមជ្ឈឹមដែលមានភាពស្មុគស្មាញ និងបទមជ្ឈិមដែលមិនមានភាពស្មុគស្មាញ ទើបក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាតមិនធ្វើការស៊ើបសួរក៏បាន។ ក្នុងករណីដែលបទល្មើសដែលត្រូវធ្វើការចោទប្រកាន់នោះមិនមានភាពស្មុគស្មាញនោះទេ នោះតំណាងអយ្យការអាចមិនធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរបាន ពោលគឺអង្គការអយ្យការអាចធ្វើការចោទប្រកាន់តាមនីតិវិធីផ្សេងទៀត។

#### ១.២.១.២. លក្ខខណ្ឌនៃទោសដែលត្រូវដាក់ពន្ធនាគារ

ការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១ (មួយ) ឆ្នាំ[23]។ ចំណុចនេះគឺចង់សំដៅដល់នៅពេល

---

[20] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៤

[21] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ៤៣

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១២២

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៤

ដែលអង្គការអយ្យការធ្វើការបើកការស៊ើបសួរហើយ នោះចៅក្រមស៊ើបសួរត្រូវវាយតម្លៃទៅលើភស្តុតាងដែលជនត្រូវចោទត្រូវប្រឈមនឹងការផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពីមួយឆ្នាំ ទើបចៅក្រមស៊ើបសួរធ្វើការពិចារណាសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទ។

**ឧទាហរណ៍** ៖ អំពើរំលោភសេចក្តីទុកចិត្ត ត្រូវដាក់ពន្ធនាគារពី៦ ខែ ទៅ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ លានរៀលទៅ ៦ ០០០ ០០០ លានរៀល[24]។ បើយើងពិនិត្យទៅលើរយៈពេលក្នុងបទល្មើសនេះ ក្នុងឃុំខ្លួនបណ្ដោះអាសន្នគឺអាចធ្វើទៅបាន។

#### ១.២.១.៣. លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទ

លក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទគឺសំខាន់ក្នុងការវិនិច្ឆ័យថា ជនត្រូវចោទគួរតែត្រូវសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្នដែរឬទេ។ អនីតិជនអាយុតិចជាង១៤ ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឲឪពុកម្ដាយ អ្នកអាណាព្យាបាល ឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រងចាំសេចក្ដីសម្រេចរបស់តុលាការ[25]។

### ១.២.២. មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

បន្ទាប់ពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានបំពេញហើយនោះចៅក្រមនឹងធ្វើការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន តាមរយៈដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដោយមានសំអាងហេតុ ហើយនៅក្នុងដីកាសម្រេចនេះក៏ត្រូវបញ្ជាក់ពីមូលហេតុទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្នដោយយោងទៅតាមស្ថានភាពចាំបាច់[26] ឬ មូលហេតុនៃការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យពិនិត្យតាមផ្លូវតុលាការនៅពេលដែលចាំបាច់[27]។

#### ១.២.២.១. មូលហេតុទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់៖

១. ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី

២. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣. ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ។

---

[24] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩២

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១២

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៥

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៣០

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥. ដើម្បីរក្សាការពារសន្តិសុខឱ្យជនត្រូវចោទ។

៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។[28]

**ដើម្បីបញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី**

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបនៃការឃុំខ្លួនអាចបញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតមានជាថ្មី ថាតើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើសដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មី ឬទេ?[29]

ជាធម្មតាសកម្មភាពនៃបទល្មើសមិនដូចគ្នាទេ បទល្មើសមួយចំនួនមានលក្ខណៈស្រាល និងបង្កព្យសនកម្មតិចតួច តែបទល្មើសខ្លះមានលក្ខណៈសាហាវឃោឃៅ និងបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរ ដែលបង្កឱ្យប៉ះពាល់ខ្លាំងដល់សន្តិសុខសង្គម និងអាចមានការប៉ះពាល់ដល់អាយុជីវិតជនរងគ្រោះជាច្រើននាក់។ ក្រោយពេលដែលជនត្រូវចោទបានប្រព្រឹត្តបទល្មើសណាមួយ ហើយត្រូវបានឃាត់ខ្លួន ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលលទ្ធភាពនៃការកើតឡើងវិញនៃបទល្មើស ឬ ការរីករាលដាលនៃបទល្មើសបន្តទៀត ពីព្រោះករណីខ្លះប្រសិនបើជនល្មើសមិនត្រូវបានឃុំខ្លួនទេ នោះជនល្មើសអាចនឹងមានលទ្ធភាពនៃការបន្តសកម្មភាពល្មើសទៀតបាន។

**ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត**

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគៀបសង្កត់សាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត ថាតើមានហេតុផលសមរម្យដើម្បីជឿជាក់ថាជនត្រូវចោទអាចគៀបសង្កត់សាក្សី ឬ ជនរងគ្រោះឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃាត់ខ្លួន)?[30]

---

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៥

[29] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្តីសម្រេច លេខ២៦ ចំណុច ក

[30] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្តីសម្រេច លេខ២៦ ចំណុច ខ

ចំពោះបទល្មើសខ្លះ គឺមានការចូលរួមប្រព្រឹត្តពីមនុស្សគ្នាច្រើន អាចជាអ្នកដែលប្រព្រឹត្តដោយផ្ទាល់(ចារី) ឬ អាចជាសហចារី អ្នកសមគំនិត និងអ្នកផ្ដើមគំនិត ជាដើម។ សកម្មភាពល្មើសទាំងនេះ អាចមានជនរងគ្រោះ ឬ សាក្សីដែលបានឃើញផ្ទាល់ភ្នែក ហើយការឃើញរបស់សាក្សីនោះជាភស្តុតាងដ៏សំខាន់សម្រាប់បង្ហាញការពិតនៃអង្គហេតុទាំងមូល។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទទេ នោះជនត្រូវចោទអាចទៅគំរាមកំហែងទៅលើសាក្សី ឬ ជនរងគ្រោះតាមវិធីផ្សេងៗ ដែលអាចធ្វើទៅបាន ដើម្បីមិនឱ្យឆ្លើយការពិតនៅចំពោះមុខតុលាការ ហេតុដូច្នេះហើយ ការឃុំខ្លួនទៅលើជនត្រូវចោទគឺមានភាពចាំបាច់ណាស់ដើម្បីទប់ស្កាត់ហេតុការណ៍នេះ។ ដូចគ្នាដែរ ជនត្រូវចោទ និងអ្នកដែលចូលរួមផ្សេងៗទៀត អាចមានការត្រូវរ៉ូវគ្នារួចទៅបំផ្លាញភស្តុតាងតាមមធ្យោបាយផ្សេងៗរបស់ពួកគេនៅពេលដែលមិនសម្រេចអំពីការឃុំខ្លួននោះ។

**<u>ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ</u>**

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរារាំងជនត្រូវចោទពីការធ្វើឱ្យខូចខាតភស្តុតាង ឬ តម្រុយជាសម្ភារៈ ថាតើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរ ឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬ តម្រុយជាសម្ភារៈ (ឧទាហរណ៍ ៖ អាវុធដែលពាក់ព័ន្ធជាមួយបទល្មើសជាដើម)?[31]

ជាធម្មតាក្រោយពីហេតុការណ៍ណាមួយបានកើតមានឡើង ក្រៅពីសាក្សី និងជនរងគ្រោះដែលបានឃើញ បានឮនូវអង្គហេតុផ្ទាល់ ក៏នៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈផ្សេងទៀត ដែលអាចបញ្ជាក់ពីការពិតនៃអង្គហេតុបានដែរ ហើយតួនាទីរបស់ចៅក្រមស៊ើបសួរ គឺស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដើម្បីបញ្ជាក់នូវការពិត។ ប្រសិនបើភស្តុតាងត្រូវបានលុបបំបាត់ នោះការពិតវាប្រាកដជាមានភាពពិបាកនៅក្នុងការស្វែងរកណាស់ ហើយយុត្តិធម៌ក៏ត្រូវបានបាត់បង់ទៅតាមនោះផងដែរ ហេតុដូច្នេះការឃុំខ្លួនបណ្ដោះអាសន្ន គឺជាករណីដែលមានភាពចាំបាច់ណាស់ ដើម្បីធានាឱ្យបានថា ជនត្រូវចោទមិនមានលទ្ធភាពទេក្នុងការទៅបំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈផ្សេងទៀតនោះទេ។

[31] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើប្រាស់បមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្ដីសម្រេច លេខ៦ ចំណុច គ

**ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី**

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានរបស់ជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធីថា តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅនៅក្រៅប្រទេសដែរឬទេ?[32]

ការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទ គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះបើទុកជនត្រូវចោទឱ្យនៅក្រៅឃុំ នោះជននោះអាចនឹងរត់គេចមិនចូលបង្ហាញខ្លួននៅតុលាការតាមការកោះហៅ ឬជនត្រូវចោទអាចនឹងភៀសខ្លួនទៅនៅក្រៅប្រទេសបាត់ ដើម្បីជៀសវាងពីការទទួលខុសត្រូវនូវអំពើជាបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

**ដើម្បីរក្សាការពារសន្តិសុខឱ្យជនត្រូវចោទ**

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឱ្យជនត្រូវចោទថាតើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬ ជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទដែរឬទេ?[33]

ជាទូទៅអំពើល្មើសតែងតែបង្កឱ្យមានព្យសនកម្ម ហើយជនរងគ្រោះ ក្រុមគ្រួសាររបស់ជនរងគ្រោះនិងអ្នកដែលបានដឹងអំពីហេតុការណ៍នេះ តែងមានអារម្មណ៍ឈឺចាប់ និងពោរពេញទៅដោយកំហឹងរហូតឈានទៅដល់ការសងសឹកទៅលើជនត្រូវចោទថែមទៀតផង។ តែការសងសឹកនៅក្រៅប្រព័ន្ធតុលាការបែបនេះ វាមិនមានភាពស្របច្បាប់នោះទេ វាមានតែអាចបន្តគំនុំ និងចងអាឃាតគ្នាមិនចេះចប់ មិនចេះហើយ ជាពិសេសវាធ្វើឱ្យសង្គមជាតិទាំងមូលគ្មានរបៀបរៀបរយ និងគ្មានសេចក្ដីថ្លៃថ្នូរ។

**ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស**

ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរក្សាសណ្ដាប់ធ្នាប់ កុំឱ្យមានភាពច្របូកច្របល់ណាមួយដែលបណ្ដាលមកពីបទល្មើសនេះ[34]។

នៅក្នុងសង្គមបទល្មើសដែលកើតមានឡើង តែងតែមានលក្ខណៈប្លែកៗពីគ្នា បទល្មើសខ្លះបណ្ដាលឱ្យមានមនុស្សរងគ្រោះថ្នាក់ជាច្រើននាក់ ហើយនឹងអាចធ្វើឱ្យសង្គមទាំងមូលជួបប្រទះនឹងភាពច្របូកច្របល់រឹករវជាអាទិ៍ ដូចជាអំពើភេរវកម្ម ការជួញដូរគ្រឿងញៀន ឬ បទឧក្រិដ្ឋកម្មសង្គ្រាម ជាដើម។ បទល្មើសទាំងនេះមានការ

---

[32] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្ដីសម្រេច លេខ៦ ចំណុច ឃ

[33] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្ដីសម្រេច លេខ៦ ចំណុច ង

[34] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ត្រង់សំអាងហេតុនៃសេចក្ដីសម្រេច លេខ៦ ចំណុច ច

លំបាកក្នុងការបង្ក្រាប ទប់ស្កាត់ និងអាចបង្កឱ្យមានចលាចលនៅក្នុងប្រទេស បង្កឱ្យមានការភ័យខ្លាចដល់ប្រជាជន ហេតុដូច្នេះ ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ជាការចាំបាច់ណាស់ដើម្បីបញ្ចៀសនូវផលប៉ះពាល់ធ្ងន់ធ្ងរ ដែលអាចកើតមានឡើងជាបន្តទៀត។

**១.២.២.២. មូលហេតុពិសេសនៃការឃុំខ្លួនបណ្តោះអាសន្ន**

ក្រៅពីមូលហេតុមួយចំនួនដែលមានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏នៅមានមូលហេតុពិសេសមួយផ្សេងទៀត ដែលបណ្តាលមកពីជនត្រូវចោទ មិនបានគោរពនូវកាតព្វកិច្ច ដែលចៅក្រមស៊ើបសួរបានកំណត់នៅក្នុងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅពេលដែរចាំបាច់។

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានចិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា ២០៨ (ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា ២១០ (ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាអាទិ៍) មាត្រា ២១៣ (ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំ-បី) ឆ្នាំ ) និងមាត្រា ២១៤ (ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ[35]។

**១.២.៣. អានុភាពនៃការឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្នមានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើស ដែលជនត្រូវចោទបានប្រព្រឹត្ត ហើយក្នុងករណីដែលមានការផ្តន្ទាទោសដាក់ពន្ធនាគារ ការឃុំខ្លួនបណ្តោះអាសន្នត្រូវរាប់បញ្ចូលដោយស្វ័យប្រវត្តិក្នុងការផ្តន្ទាទោសជាស្ថាពរ។ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងចិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល[36]។

**ឧទាហរណ៍** ៖ ជនត្រូវចោទដែលត្រូវបានចោទប្រកាន់ពីបទ **ឃាតកម្ម** ហើយត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល **៦ (ប្រាំមួយ) ខែ** នៅពេលដែលប្រកាសសាលក្រមតុលាការបានផ្តន្ទាទោសដាក់ពន្ធនាគារជនជាប់ចោទចំនួន **១០ (ដប់)** ឆ្នាំ ដូចនេះមានន័យថាជនជាប់ចោទត្រូវអនុវត្តទោសបន្ថែមទៀតចំនួនត្រឹមតែ **៩ (ប្រាំបួន) ឆ្នាំ** និង **៦ (ប្រាំមួយ)ខែ** ប៉ុណ្ណោះ។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៣០ កថាខណ្ឌទី១

[36] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥១

# ជំពូកទី២
# ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្ដោះត្រូវបានច្បាប់បញ្ញត្តិជាបីប្រភេទ ដែលរួមមាន ថិរវេលាទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ និងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះករណីពិសេស។

## ១.១. ថិរវេលាទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលាទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានបែងចែកជាពីរប្រភេទ គឺថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះនីតិជន និងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជន។

### ១.១.១. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះនីតិជន

#### ១.១.១.១. ករណីបទឧក្រិដ្ឋ

ចំពោះនីតិជន ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែ ២ (ពីរ) ដងគត់[37]។

#### ១.១.១.២. ករណីបទមជ្ឈិម

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់ មិនឱ្យលើសពី ២ (ពីរ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[38]។

### ១.១.២. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជន

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ[39]។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៨

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៩

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១២

ក្នុងករណីដែលអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើបានដែលមានការកំណត់ដោយច្បាប់។

**១.១.២.១. ករណីបទឧក្រិដ្ឋ**

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅៈ

១. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។

២. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេកាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ[40]។

**១.១.២.២. ករណីបទមជ្ឈិម**

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ ៖

១. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជននេះ មានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។

២. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពីអាយុ ១៦ (ដប់ប្រាំមួយ)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី ១ និងចំណុចទី ២ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ[41]។

## ១.២. ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវបានឃុំខ្លួននោះ ចិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើមាន[42]។

កាលណាបុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានឃុំខ្លួននោះចិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើមាន[43]។

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៣

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៤

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០២

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៩៤

## ១.៣. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ

ក្នុងករណីដែលមានបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬ បទឧក្រិដ្ឋសង្រ្គាមការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើស ១ (មួយ) ឆ្នាំ បានទេចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់[44]។

## ១.៤. ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរ ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ។ កាលណាជនត្រូវចោទមានមេធាវីអមនោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនរបស់កូនក្តីរបស់ខ្លួន។

ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្តោះអាសន្នតាមដីកាដោយមានសំអាងហេតុ។ នៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការខ្លួនបណ្តោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកានេះត្រូវឱ្យដំណឹងបន្ទាន់ដល់ជនត្រូវចោទ[45]។

## ១.៥. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះមូលហេតុពិសេស

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ កាលណាចៅក្រមស៊ើបសួរ សម្រេចថាឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុគេចវេះពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ ក្នុងករណីដែរជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមធ្យោបាយការពារកូនក្តីរបស់ខ្លួន។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទ តាមដីកាដែលមានសំអាងហេតុ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមាត្រានេះមិនអាចឱ្យលើសពី៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែចំពោះអនីតិជន[46]។

## ១.៦. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្រោយចេញដីកាដំណោះស្រាយ

ដីកាដំណោះស្រាយមានអានុភាពបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅពេលដែលដែលចៅក្រមស៊ើបសួរសម្រេចរក្សាទុកជនត្រូវចោទនៅ

---

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១០

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១១

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៣០

ជាប់ឃុំបណ្តោះអាសន្នបន្តទៀត ចៅក្រមស៊ើបសួរត្រូវចេញនូវសេចក្តីសម្រេចដោយឡែកពីដីកាដំណោះស្រាយគឺដីកាសម្រេចរក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្ន។ នៅក្នុងដីកានោះចៅក្រមស៊ើបសួរត្រូវយោងនូវមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំបណ្តោះអាសន្ន លែងមានអានុភាពក្នុងរយៈពេល ៤ (បួន) ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ (បួន) ខែនោះទេ នោះជនត្រូវចោទនឹងត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង[47]។

[47] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៤៩

# ជំពូកទី៣
# នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន

តាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងនូវលំហូរនៃនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នដែលរួមមានដូចជា ៖ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ កិច្ចបង្ហាញខ្លួនលើកដំបូង ការពិភាក្សាដេញដោលចំពោះមុខ ការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន និងការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន។

## ១.១. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ក្នុងករណីដែលចៅក្រមស៊ើបសួរបានសម្រេចចិត្តមិនដាក់ជនត្រូវចោទក្នុងឃុំទេ តុលាការអាចធ្វើការដាក់ជនត្រូវចោទនោះអោយស្ថិតនៅក្រោមការត្រួតពិនិត្យបាន។ យោងតាមមាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈជា ចារី ជាអ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត[48]។

## ១.២. កិច្ចបង្ហាញខ្លួនលើកដំបូង

ការបង្ហាញខ្លួនលើកដំបូង ត្រូវបានធ្វើឡើងនៅពេលដែលជនត្រូវចោទត្រូវបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ តាមរយៈ ៖

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- ដីកាបង្គាប់ឱ្យចូលខ្លួន៖ គឺជាបញ្ជាដល់បុគ្គលណាម្នាក់ អោយចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់អោយចូលខ្លួន អាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។
- ដីកាបង្គាប់ឱ្យនាំខ្លួន៖ គឺជាបញ្ជាដល់កម្លាំងសាធារណៈ ដោយចាប់ នឹងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់អោយចូលខ្លួន អាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។
- ដីកាបង្គាប់ឱ្យចាប់ខ្លួន៖ ដីកាបង្គាប់អោយចាប់ខ្លួន អាចត្រូវចេញទៅលើជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ចៅក្រមស៊ើបសួរចេញដីកាបង្គាប់អោយឃុំខ្លួនលុះត្រាតែ៖

i.បទល្មើសដែលចោទប្រកាន់ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១២៦

ii.បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជណាចក្រកម្ពុជា។

ដីកាបង្គាប់អោយចាប់ខ្លួនគឺជាបញ្ជាៈ

_ដល់កម្លាំងសាធារណៈ អោយស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

_ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអោយទទួល និងឃុំខ្លួនបុគ្គលនោះ។

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទប្រាប់ជននេះឱ្យបានដឹងពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី។ និទ្ទេសស្ដីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬ ក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ ក្នុងករណីជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវបានទទួលដំណឹងថា ៖ ក. ខ្លួនត្រូវតែជូនព័ត៌មាន ដល់ចៅក្រមស៊ើបសួរ នៅពេលដែលខ្លួនផ្លាស់ប្ដូរអាសយដ្ឋាន។ ខ. គ្រប់ការឱ្យដំណឹងដែលបានធ្វើតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើយដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់។ ការឱ្យដំណឹងព្រមទាំងការប្រកាសស្ដីអំពីការផ្លាស់ប្ដូរអាសយដ្ឋាននោះ ត្រូវតែចុះក្នុងកំណត់ហេតុនៅពេលដែលចូលបង្ហាញខ្លួនលើកដំបូង[49]។ ទំព័រនីមួយៗនៃកំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនលើកដំបូង ដូចមានចែងនៅក្នុងមាត្រា ១៤៣ (ការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និងសាមីខ្លួន នៅរឹមទំព័រ។ កាលណាជនត្រូវចោទបានឆ្លើយ ចម្លើយទាំងនេះត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវនៅក្នុងកំណត់ហេតុ[50]។

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយ

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៤៣

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៤១

អ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬ សាក្សីទេ[51]។

## ១.៣. ការពិភាក្សាដេញដោលចំពោះមុខ

ការពិភាក្សាដេញដោលគឺជានិតិវិធីបន្ទាប់នៅក្រោយពេលបញ្ចប់នីតិវិធីបង្ហាញខ្លួនលើកដំបូង។ ចៅក្រមស៊ើបសួរត្រូវធ្វើបន្តនូវនីតិវិធីពិភាក្សាដេញដោលចំពោះមុខ ដើម្បីឈានដល់ការសម្រេចអំពីការឃុំខ្លួន ឬ មិនឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ។ ដើម្បីធានាបាននូវការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងនីតិវិធីពិភាក្សាដេញដោលចំពោះមុខ គប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីការពារជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន[52]។

## ១.៤. ការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ន តាមដីកាដោយមានសំអាងហេតុ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដូចបានចែងនៅក្នុងមាត្រា ២២០ (និយមន័យដីកាបង្គាប់ឱ្យឃុំខ្លួន) មាត្រា ២២១ (និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន) និងមាត្រា ២២២ (ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ[53]។

## ១.៥. ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន

ចំពោះការចេញដីកាបង្គាប់អោយឃុំខ្លួន គឺចេញដោយចៅក្រមស៊ើបសួរដោយយោងតាមមាត្រា២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាដីកាដែលបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និង ឱ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវ

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ១៤៤

[52] លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ទំព័រទី១

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៦

ចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន[54]។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន រក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬ ចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[55]។ និទ្ទេសដែលត្រូវចុះនៅកលើដីកាបង្គាប់អោយឃុំខ្លួនបណ្តោះអាសន្ន គឺត្រូវមានអត្តសញ្ញាណរបស់ជនត្រូវចោទ ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់កំណត់ និងបង្ក្រាបបទល្មើសនេះ ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។ [56]

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២២០

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២២២

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២២១

# ជំពូកទី៤
# ការមិនឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរមានអំណាចក្នុងការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ និងមានសិទ្ធិអំណាចនៅក្នុងការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទផងដែរ ដោយជំនួសមកវិញនូវវិធានត្រួតពិនិត្យតាមផ្លូវតុលាការវិញ។

## ១.១. ការមិនឃុំខ្លួនបណ្តោះអាសន្ន

### ១.១.១. ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន

ដូចដែរបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចមិនឃុំខ្លួនទៅលើជនត្រូវចោទបានដោយយោងតាមមាត្រា២០៧។ កាលណាចៅក្រមស៊ើបសួរ ដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលសុំឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននោះ មិនព្រមធ្វើតាមការសុំឱ្យឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរ ត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដោយមិនចាំបាច់មានសំអាងហេតុទេ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ។[57]

### ១.១.២. ការសម្រេចដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ហើយត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន[58]។ មួយវិញទៀត កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទ ដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម[59]។ ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំអាចធ្វើឡើងដោយចៅក្រមស៊ើបសួរ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា និងតាមបណ្តឹងរបស់ជនត្រូវចោទ។

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២០៧
[58] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៨
[59] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៧៦ កថាខណ្ឌទី១

#### ១.១.២.១. ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា។ កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃបន្ទាប់ពីការបញ្ជូនសំណុំរឿងនៅព្រះរាជអាជ្ញា។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន[60]។

#### ១.១.២.២. ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[61]។

#### ១.១.២.៣. ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជនត្រូវចោទអាចដាក់ពាក្យសុំសារជាថ្មីម្តងទៀត ទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួររយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើប-សួរ ឬ សភាស៊ើបសួរ ត្រូវសម្រេចលើពាក្យនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើប-សួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[62]។

### ១.២. ការត្រួតពិនិត្យតាមផ្លូវតុលាការ

កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចដាក់ជននោះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន[63]។ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យស្ថិតនៅ

---

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៥

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៦

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៧

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២១៨ កថាខណ្ឌទី៣

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមគំនិតផ្តើមផ្ទាល់ខ្លួន ឬ តាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។ នៅពេលដែលចៅក្រមស៊ើបសួរសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវចេញនូវ ដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយដីកានេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[64]។

### ១.២.១. ភាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬ ច្រើនដូចជា ៖

១. មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

២. មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣. មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤. ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥. ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦. ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧. មិនត្រូវបើកបររថយន្ត។

៧. មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩. ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០. មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១. ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។[65]

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២២៦

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២២៣

### ១.២.២. ការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីបំពានកាតព្វកិច្ចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា ២០៨ (ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា ២១០ (ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាអាទិ៍) មាត្រា ២១៣ (ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ) និងមាត្រា ២១៤ (ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ នៃក្រមនីតិវិធីអ៊ីព្រហ្មទណ្ឌក៏ដោយ[66]។

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧, មាត្រា ២៣០ កថាខណ្ឌទី១

# សេចក្តីសន្និដ្ឋាន

ក្នុងការស្វែងរកឱ្យឃើញនូវអត្ថិភាពនៃបទល្មើសយ៉ាងពិតប្រាកដ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបែកចែកនូវនីតិវិធីជាច្រើនដោយមានការបែងចែកជាដំណាក់កាលផ្សេងៗដោយក្នុងនោះរួមមាន ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលនៃការស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។នៅក្នុងការស្រាវជ្រាវសារណាមួយនេះ ក្រុមខ្ញុំបាទបានធ្វើការសិក្សានៅក្នុងដំណាក់កាលស៊ើបសួរ ដោយផ្តោតទៅលើដំណាក់កាលស៊ើបសួរដោយក្រុមខ្ញុំបាទបានជ្រើសរើសនូវប្រធានបទ **ការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលចៅក្រមស៊ើបសួរ។**

តួនាទីចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលនៃការស៊ើបសួរ គឺដើម្បីស្វែងរកការពិត និងស្វែងរកនូវភស្តុតាងនៃសំណុំរឿងព្រហ្មទណ្ឌ។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានមួយក្នុងចំណោមវិធានការនិរន្តរាយទាំងអស់ ដែលបានផ្តល់អំណាចទៅឱ្យចៅក្រមស៊ើបសួរធ្វើការសម្រេចឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ ដើម្បីធានានូវកិច្ចដំណើរការនៃនីតិវិធីស៊ើបសួររបស់ខ្លួនក្នុងការស្វែងរកឱ្យឃើញនូវអត្ថិភាពនៃអង្គហេតុ និងស្វែងរកការពិតនៃសំណុំរឿង។ទោះបីជាចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្ននៅតែមានភាពចាំបាច់ ប៉ុន្តែទាល់តែមានការប្រកាសជាស្ថាពរនៃសាលក្រម ឬសាលដីកា តែប៉ុណ្ណោះ ទើបអាចបញ្ជាក់បានថាជនណាម្នាក់មានទោស។ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទមិនមែនមានន័យថាជននោះមានទោសនោះទេ ពោលគឺវាគ្រាន់តែជាវិធានការមួយដើម្បីឃាត់ជនត្រូវចោទអោយនៅក្នុងពន្ធនាគារដើម្បីរកឱ្យឃើញថាជនត្រូវចោទនោះមានទោស ឬ គ្មានតែប៉ុណ្ណោះ។

ចៅក្រមស៊ើបសួរគប្បីពិនិត្យនូវលក្ខខណ្ឌមួយចំនួនដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្នដូចជា លក្ខខណ្ឌទាក់ទងនឹងបទល្មើសដែលត្រូវចោទប្រកាន់ លក្ខខណ្ឌទាក់ទងនឹងទោសដែលត្រូវដាក់ពន្ធនាគារ និងលក្ខខណ្ឌនៃអាយុរបស់ជនត្រូវចោទព្រោះថាអនីតិជនដែលមានអាយុតិចជាង ១៤ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ននោះទេ។ទោះបីជាគោលការណ៍សេរីភាពត្រូវបានទទួលស្គាល់ និងយកមកអនុវត្តក៏ពិតមែន ប៉ុន្តែនៅក្នុងករណីចាំបាច់មួយចំនួន ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានដែលត្រូវយកមកអនុវត្តដោយខានពុំបាន។

ការឃុំខ្លួនបណ្តោះអាសន្ននេះមានការប៉ះពាល់នូវសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗហើយបុគ្គលដែលត្រូវបានឃុំខ្លួននោះត្រូវបានជាប់ក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ទើបចៅក្រមស៊ើបសួរគប្បីពិចារណាអោយបានគ្រប់ជ្រុងជ្រោយជាមុនសិន។ចៅក្រមស៊ើបសួរគប្បីពិនិត្យឱ្យបានច្បាស់លាស់នូវលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មុនឈានដល់ការសម្រេចចិត្តថាគួរឃុំខ្លួន ឬ មិនឃុំខ្លួនជនត្រូវចោទ។ បន្ថែមពីនេះទៀត ចៅក្រមស៊ើបសួរគប្បីអនុវត្តឱ្យបានគ្រប់នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ដែល

រួមមាននីតិវិធីនៃការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ នីតិវិធីនៃការបង្ហាញខ្លួនលើកដំបូង និងនីតិវិធីនៃការពិភាក្សាដេញដោលចំពោះមុខ។ ក្រោយពីពិនិត្យនូវលក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន និងអនុវត្តនូវនីតិវិធីដែលបានរៀបរាប់ខាងលើនេះហើយ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាការឃុំខ្លួនបណ្ដោះអាសន្នជាការចាំបាច់ ចៅក្រមស៊ើបសួរត្រូវតែបង្ហាញពីមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលជាមូលហេតុទូទៅ ឬ ក៏មូលហេតុពិសេសដែលជាមូលហេតុនៃការគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវធ្វើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងចេញនូវដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទដើម្បីបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ។

សរុបសេចក្ដីមក ចៅក្រមស៊ើបសួរមានទំរង់ជាការកាត់បន្ថយនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទ ដោយការធ្វើការឃុំខ្លួនបណ្ដោះអាសន្ន ប៉ុន្តែការប្រតិបត្តិវិធាននេះក្នុងគោលបំណងដើម្បីរក្សាសុវត្ថិភាព និងសន្តិសុខចំពោះជនត្រូវចោទក៏ដូចជាសង្គមផងដែរ។ ការអនុវត្តនេះមានសារៈសំខាន់ខ្លាំងដោយសារតែវាជួយសម្រួលនូវកិច្ចដំណើរការនីតិវិធីនៃការស៊ើបសួរ និងដើម្បីស្វែងរកការពិត រួមទាំងយុត្តិធម៌ជូនជនរងគ្រោះ។

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងតាមរយៈការសាកសួរមន្ត្រីដែលអនុវត្តច្បាប់នៅសាលាដំបូងរួចមក យើងសង្កេតឃើញថា គប្បីមានការកែតម្រូវនូវចំណុចមួយចំនួនក្នុងគោលបំណងដើម្បីឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពតាមការកំណត់នៅក្នុងទ្រឹស្តីគតិយុត្ត និងទទួលបានទំនុកចិត្តពីសាធារណជន ក៏ដូចជាជនត្រូវចោទ យើងខ្ញុំសូមលើកយកអានុសាសន៍មួយចំនួនដូចខាងក្រោម ៖

១. ធានាឱ្យបានគោលការណ៍សេរីភាពរបស់ជនត្រូវចោទ ពោលគឺជៀសវាងនៅក្នុងករណីមួយចំនួនដែលការឃុំខ្លួនបណ្តោះអាសន្នមិនមានភាពចាំបាច់។

២. ចំពោះកិច្ចបង្ហាញខ្លួនលើកដំបូង គួរតែធ្វើដាច់ដោយឡែក ហើយត្រូវប្រាប់ពីសិទ្ធិដែលធានាដោយក្រមនីតិវិធីព្រហ្មទណ្ឌទាំងអស់ដល់ជនត្រូវចោទ ដើម្បីឱ្យជនត្រូវចោទមានលទ្ធភាពក្នុងការប្រើប្រាស់នូវសិទ្ធិទាំងនោះ។

៣. ចំពោះនីតិវិធីនៃការសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន គួរអនុវត្តឱ្យបានត្រឹមត្រូវតាមការកំណត់នៅក្នុងទ្រឹស្តីគតិយុត្ត ដោយធ្វើទៅតាមលំហូរនៃនីតិវិធីដូចជា ការបង្ហាញខ្លួនលើកដំបូង កិច្ចពិភាក្សាដេញដោលចំពោះមុខ និងការសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្ន។

៤. ចំពោះនីតិវិធីនៃការពិភាក្សាដេញដោលចំពោះមុខ គួរបើកជាសវនាការមុនអង្គសេចក្តីមួយនៅក្នុងសាលសវនាការជាសាធារណៈ ហើយធ្វើយ៉ាងណាអោយមាននូវវត្តមានរបស់ភាគីពាក់ព័ន្ធចូលរួមក្នុងនីតិវិធីនេះ ដូចជា តំណាងអយ្យការ មេធាវីការពារសិទ្ធិជនត្រូវចោទ និងជនត្រូវចោទ ដើម្បីធ្វើការពិភាក្សាដេញដោលពីមូលហេតុ ក៏ដូចជាលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន។ ម្យ៉ាងទៀត វានឹងធ្វើឱ្យជនត្រូវចោទអស់ចិត្ត និងទទួលយកការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នមកលើខ្លួន។

ក្រៅពីនេះ ក្រោយពេលដែលចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទរួចហើយ ជននោះត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងពន្ធនាគារដើម្បីរង់ចាំការកាត់ក្តីដោយចៅក្រមជំនុំជម្រះ។ ទន្ទឹមនឹងនោះយើងខ្ញុំទាំងពីរនាក់យល់ឃើញថា ៖

១. ជនត្រូវចោទដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារនោះ គឺមានភាពខ្វះខាតនៅជំនួយផ្នែកច្បាប់ ហើយពួកគេក៏មានជីវភាពខ្វះខាត ដែលធ្វើអោយពួកគេគ្មានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិរបស់គាត់តាមផ្លូវច្បាប់ ដូច-ជាសិទ្ធិក្នុងការស្នើសុំនៅក្រៅឃុំ សិទ្ធិក្នុងការប្តឹងជិតចិត្ត សិទ្ធិក្នុងការប្តឹងទៅនឹងដីកាផ្សេងៗរបស់ចៅក្រមដែលច្បាប់បានផ្តល់ជូនគាត់ ជាដើម។

២. គួរមានការពន្លឿននូវនីតិវិធី ចៅក្រមស៊ើបសួរគួរផ្តល់អាទិភាពចំពោះសំណុំរឿងព្រហ្មទណ្ឌទាំងឡាយណាដែលមានជនត្រូវចោទនៅជាប់ឃុំបណ្តោះអាសន្ន ជាពិសេសគឺសំណុំរឿងដែលមានជនត្រូវចោទជាអនីតិជន ព្រមទាំងធានាឱ្យមានការសហការបានល្អជាមួយស្ថាប័នដែលពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការស៊ើបសួរ។

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

-ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៥, ១០ សីហា ២០០៧។

-ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/០២២, ៣០ វិច្ឆិកា ២០០៩។

-ច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិ-វិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ឆ្នាំ២០១៣។

## ២. សៀវភៅ និងឯកសារផ្សេងៗ

-លិខិតលេខ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | លិខិតណែនាំរបស់ក្រសួងយុត្តិធម៌ស្តីពីការដាក់ឱ្យប្រើនូវរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន |
| ០២ | ច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា២៤៧ មាត្រា៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៦១៣/០០៩, ០៩ មិថុនា ឆ្នាំ២០១៣ |
| ០៣ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| ០៤ | កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង |
| ០៥ | កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ |
| ០៦ | ដីកាសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន |
| ០៧ | ដីកាបង្គាប់ឱ្យឃុំខ្លួន |
| ០៨ | ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន |
| ០៩ | ដីកាបញ្ជូនឱ្យឆ្លើយ |
| ១០ | ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន |
| ១១ | ដីកាបង្គាប់ឱ្យដោះលែង |
| ១២ | ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ |
| ១៣ | ដីកាបង្គាប់ឱ្យចាប់ខ្លួន |
| ១៤ | ដីកាសម្រេចពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន |
| ១៥ | ដីកាបង្គាប់ឱ្យពន្យាពេលឃុំខ្លួនជាបណ្ដោះអាសន្ន |
| ១៦ | ដីកាដំណោះស្រាយ |

**ឧបសម្ព័ន្ធទី១**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងយុត្តិធម៌**

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មករា ឆ្នាំ២០១៤

លេខ ១៧០ កសល.រាប.រាប/១៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូងរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ថាកន្លងមកក្រសួងយុត្តិធម៌បានផ្តល់នូវរូបមន្តនៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្នប្រើប្រាស់សាកល្បង ឃើញថានៅមានការខ្វះចន្លោះដែលមិនអាចធានាបាននូវការជឿជាក់ពីសំណាក់សាធារណៈជន។ ដូច្នេះក្រសួងយុត្តិធម៌បានបង្កើតរូបមន្តថ្មីដែលអាចបង្ហាញពីតម្លាភាព និងគណនេយ្យភាពក្នុងការធ្វើសេចក្តីសម្រេច ដែលអាចពង្រឹងនូវការជឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌សូមធ្វើការណែនាំសម្រាប់ការបំពេញតាមចំណុចមួយចំនួន ដែលមាននៅក្នុងរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមគំរូថ្មីនេះដូចតទៅ ៖

- នៅផ្នែកខាងដើមនៃរូបមន្តពុំមានអ្វីផ្លាស់ប្តូរច្រើននោះឡើយ ហើយក៏ពុំមានអ្វីដែលពិបាកយល់ក្នុងការបំពេញនោះទេ។

នៅផ្នែកនេះ: ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័តមានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ឃុំខ្លួន ឬ មិនឃុំខ្លួន ដូចជាជនត្រូវចោទ ជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬ ជនត្រូវចោទ ជាចាស់ជរា។ល។ ក្នុងស្ថានភាពបែបនេះ បើអាចជៀសវាងបាន មិនគួរគេប្បីសម្រេចឃុំខ្លួននោះឡើយ។

ដើម្បីធានាបានករណីខាងលើនេះ នៅក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសំរេចថាត្រូវឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយប្រើគំរូតាមរូបមន្តថ្មីនេះ។

ការប្រើនីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលបាននូវអំណះអំណាងគ្រប់ជ្រុងជ្រោយក្នុងការសម្រេច ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

1. ចំណុចលេខ១តូចនេះ: ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

2. ចំណុចលេខ២តូចនេះ: ចៅក្រមស៊ើបសួរត្រូវសរសេរសង្ខេបពីអង្គហេតុនៃរឿងក្តី។

3. ចំណុចលេខ៣តូចនេះ: ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ២ឬ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឲ្យឃុំខ្លួន ឬ មិនឲ្យឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាង អយ្យការបានលើកឡើង។

4. ចំណុចលេខ៤តូចនេះ: ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់ ឬ ការអះអាង របស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ២ឬ៣ បន្ទាត់។

II. សំអាងហេតុសេចក្តីសម្រេច ៖

5. ចំណុចលេខ៥តូចនេះ: ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់។

6. ចំណុចលេខ៦តូច ចៅក្រមស៊ើបសួរ ត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ។

ទន្ទឹមនេះ នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់បង្ហាញពីសំអាងហេតុសំរាប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬ មិនត្រូវយកមកអនុវត្ត ដែលមានជាអាទិ៍ដូចខាងក្រោម៖

ក. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

ខ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត - តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)?

គ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរារាំងជនត្រូវចោទពីការធ្វើអោយខូចភស្តុតាង ឬ តម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬ ទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឧ: អាវុធពាក់ព័ន្ធនឹងបទល្មើសជាដើម?

ឃ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?

ង. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទ - តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរឬទេ?

ច. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។

ឆ. ចៅក្រមស៊ើបសួរក៏គួរពិចារណាពីផលប៉ះ/ហានិភ័យជាសក្តានុពលដើម្បីជាយុត្តិកម្មដល់ការដាក់នរណាម្នាក់ក្នុងការឃុំជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីផលប៉ះដែលអាចបំបាត់ហានិភ័យនេះ ឧទាហរណ៍: ការងារជាប់លាប់នៅក្នុងសហគមន៍ ចំណងគ្រួសារជាដើម។ល។

នៅក្នុងផ្នែកចុងក្រោយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាស់ នូវមូលហេតុមួយ ឬច្រើន ក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសំរេចរបស់ខ្លួនក្នុងការឃុំខ្លួន។ ក្នុងផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ផងដែរ នូវមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ ថិរវេលានេះ អាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ (សូមពិនិត្យមើលតារាងខាងក្រោម)។ នៅទីបញ្ចប់ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពនោះ ចៅក្រមត្រូវបង្ហាញថាគ្មានការដាក់កាតព្វកិច្ចណាមួយតាមរយៈការដាក់ឲ្យស្ថិតនៅ

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងមានលក្ខណៈតឹងរឹងគ្រប់គ្រាន់ ដើម្បីសម្រេចបាន គោលដៅនានា ដូចបានកំណត់នៅក្នុងផ្នែកខាងដើមនោះឡើយ។

ចៅក្រមស៊ើបសួរត្រូវសម្រេចផងដែរ ពីរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីនេះ។ តារាងខាងក្រោមបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន សំរាប់ប្រភេទនីមួយៗនៃរឿងក្តី។

| ប្រភេទនៃបទល្មើស និង មាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជនត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យារថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៦ខែ | ៦ខែ + ៦ខែ |
| បទមជ្ឈិម - មាត្រា២០៩ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៤ខែ | ២ខែ - ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ -មាត្រា២១៣ | ១៤ - ១៦ឆ្នាំ | ៤ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| មជ្ឈិម - មាត្រា២១៤ | ១៤ - ១៦ ឆ្នាំ | ២ខែ ឬ ១/២ នៃអប្បបរមានៃ ទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបា. ឡើយ |
| បទឧក្រិដ្ឋ -មាត្រា២១៣ | ១៦ - ១៨ឆ្នាំ | ៦ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៦ - ១៨ឆ្នាំ | ៤ខែ ឬ ១/២ នៃ អប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |

ចៅក្រមស៊ើបសួរត្រូវធ្វើការកត់សំគាល់ថា ក្នុងករណីបទមជ្ឈិម អប្បបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្ដាល ប្រសិនបើជនត្រូវចោទជាអនីតិជន នៅពេលប្រព្រឹត្តបទល្មើស (មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ)។

ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

ផ្នែកបញ្ចប់នៃរូបមន្តនេះ គឺជាបង្កាន់ដៃដែលបញ្ជាក់ថាបានប្រគល់ - បុគ្គលដែលបញ្ជូនដីកានេះត្រូវតែចុះហត្ថលេខាលើដីកានេះ ដើម្បីបញ្ជាក់ថាដីកានេះត្រូវបានបញ្ជូនហើយ។ អ្នកទទួលត្រូវចុះហត្ថលេខាលើដីកានេះផងដែរ បន្ទាប់ពីបានទទួល។ ជនត្រូវចោទត្រូវបានគេប្រាប់ឲ្យដឹងអំពីសិទ្ធិប្ដឹងឧទ្ធរណ៍របស់គេ និងពេលកំណត់ប្ដឹងឧទ្ធរណ៍។

ទទួលបានការណែនាំនេះ សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព។

សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។/

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានៈ

ផ្ទុនភ្ជាប់ :

- គំរូរូបមន្តដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ០១ច្បាប់

ចម្លងជូន :

- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍

"ដើម្បីជូនជ្រាប"

**ឧបសម្ព័ន្ធទី២**

រដ្ឋសភា
ចូល លេខ ១៥៧៧
ថ្ងៃទី ៣០/៥/ ឆ្នាំ២០១៣ ម៉ោង
បញ្ជូនទៅ

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៥

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨
## មាត្រា៣៧២ និងមាត្រា៣៨២
## នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា មួយ.-**

មាត្រា២៤៧ (ដីកាដំណោះស្រាយ) មាត្រា៣៦៨ (រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់) មាត្រា៣៧២ (បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី) និងមាត្រា៣៨២ (រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ២៤៧ថ្មី.- ដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ ។

ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ ៖

១- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។

២- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។

៣- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

៤- ករណីដែលបណ្តឹងអាជ្ញារលត់ ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

Rol

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុនឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថាឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការនិងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៣៦៨ថ្មី._ រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់**

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត ៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាម

បទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

## មាត្រា ៣៧២ថ្មី.- បណ្ដឹងទាស់ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចប្ដឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្ដឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។

បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

បណ្ដឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្ដឹងទាស់ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកទៅអនុវត្តលើបុគ្គលដែលតុលាការប្រកាសថា ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៨២ថ្មី.- រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកជាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលផុតកំណត់ប្តឹងទាស់ ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

នស/រកម.០៦១៣.០០៧

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ**

**សូមឡាយព្រះហស្ថលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ហត្ថលេខា

**អង្គ វង្ស វឌ្ឍនា**

លេខ: ៥៩៣ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៦ ឆ្នាំ២០១៣

**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល

លេខ: 1383 ដក.សស.២០

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**យើង** **តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។
- បានឃើញ របាយការណ៍សរុបលេខ: ២០៤ រ.ប.ក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលស្រុកស្អាង ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា:

១.គោត្តនាម-នាម ៖ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរនេសាទ មានទីកន្លែងកំណើតនៅភូមិរកា ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល និងមានទីលំនៅបច្ចុប្បន្ននៅភូមិរកា ឃុំក្រាំងយ៉ូ ខេត្តកណ្ដាល ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (រស់) ប្រពន្ធឈ្មោះ ; កូនគ្មាន ទោសពីមុនគ្មាន ជានីតិជន ។ (ឃាត់ខ្លួន)

២.គោត្តនាម-នាម ៖ ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិក្បាលកោះតូច ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្ដាល និងមានទីលំនៅបច្ចុប្បន្ននៅភូមិរកា ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ ; (រស់) ប្រពន្ធឈ្មោះ មានកូនចំនួន ០២នាក់ ជានីតិជន ។ (គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ៖**

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១១ និង ២០នាទី ក្រោមទទួលបានពត៌មានពីប្រជាពលរដ្ឋល្អថា មានករណីគ្រឿងញៀននៅចំណុចផ្ទះឈ្មោះ ភេទប្រុស អាយុ ៣៦ឆ្នាំ (គេចខ្លួន) ស្ថិតនៅភូមិរកា ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល ។ ភ្លាមនោះកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលក្រាំងយ៉ូវ សហការជាមួយកម្លាំងប្រជាការពារឃុំក្រាំងយ៉ូវ បានចុះទៅដល់កន្លែងកើតហេតុ ខណៈពេលជនសង្ស័យទាំងពីរនាក់ បានឃើញសមត្ថកិច្ចក៏បានរត់គេចខ្លួន បន្ទាប់មកកម្លាំងសមត្ថកិច្ចក៏បានដេញតាម និងឃាត់ខ្លួនជនសង្ស័យឈ្មោះ ភេទប្រុស អាយុ ២០ឆ្នាំ ចំណែកឈ្មោះ ភេទប្រុស អាយុ ៣៦ឆ្នាំ បានរត់គេចខ្លួនបាត់ រួចកម្លាំងសមត្ថកិច្ចក៏បានពិនិត្យមើលនៅកន្លែងរកឃើញម្សៅក្រាមពណ៌សថ្លាសង្ស័យថាជាសារធាតុញៀន (ម៉ាទឹកកក) ចំនួន ០១កញ្ចប់តូច រួចក៏នាំជនសង្ស័យឈ្មោះ ; ភេទប្រុស អាយុ ២០ឆ្នាំ បញ្ជូនមកកាន់ប៉ុស្តិ៍រដ្ឋបាលក្រាំងយ៉ូវដើម្បីសាកសួរ និងចាត់ការតាមនីតិវិធី ។

អាស័យដ្ឋាន: ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal Province

អំពើខាងលើជាបទល្មើស៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកោ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**<u>សម្រេច</u>**

បើតាមការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ

☑ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យលើ៖

១.ឈ្មោះ: ភេទប្រុស អាយុ ២០ឆ្នាំ (ឃាត់ខ្លួន)

២.ឈ្មោះ: ភេទប្រុស អាយុ ៣៦ឆ្នាំ (គេចខ្លួន)

□ ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ៖..............................................................
.............................................................................................................................។
.............................................................................................................................

☑ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន៖..............................................................
.............................................................................................................................។
.............................................................................................................................

ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅ[illegible] ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

**តំណាងអយ្យការ**

ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
មន្ទីរស៊ើបសួរអក្សរ "១"
សំណុំរឿងលេខ:
ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

## កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣,១៤៤,២៤០ និងមាត្រា ២៤១ [illegible] ក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែធ្នូ ថ្ងៃទីម្ភៃមួយ វេលាម៉ោង បួន រសៀល ។

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

អមដោយលោក ជាក្រឡាបញ្ជី ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម ៖

នាមត្រកូល និងនាមខ្លួន: ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតសង្កាត់បឹងកាង ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្នភូមិព្រែកឡេវ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (ស) ប្រពន្ធឈ្មោះ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារចំនួន០២លើក ។

☐ជននេះបានប្រកាសប្រាប់ថា: ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ ឆ្នាំ ដែលកំពុងស្ថិតនៅលំនៅឋានបច្ចុប្បន្ន ។

-ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ: ..........................................................................

..........................................................................................................................

☐ជននេះ: ☐ ចេះនិយាយ ☐ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

☐ជននេះ: ☐មិនចេះនិយាយ☐មិនចេះអាន☐ចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ: យើងបានប្រាប់ដល់ជននេះឱ្យបាន ដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្ដឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ដកសស/២០ ចុះថ្ងៃទី ខែ. ឆ្នាំ២០២០ ដែលជាហេតុនាំឱ្យមានការបង្ហាញខ្លួនជននេះ នៅចំពោះមុខយើង ព្រមទាំងបានប្រាប់ដល់ជននេះ ឱ្យដឹងពីបទចោទប្រកាន់ចំពោះរឿងរ៉ាវដូចខាងក្រោម:

..........................................................................................................................

..........................................................................................................................

..........................................................................................................................

យើងបានជូនដំណឹងដល់ជននេះថា: យើងគ្រោងនឹងដាក់ជននេះឱ្យស្ថិតក្រោមការពិនិត្យចំពោះរឿងរ៉ាវ ដែលយើងទើបនឹងរៀបរាប់ឱ្យជននេះដឹងយ៉ាងច្បាស់ ។

☐ លោក/លោកស្រី .................................................. ជាមេធាវី មានអត្តលេខ: .................................................. នៃជនត្រូវចោទ ដែលត្រូវបានកោះហៅនៅថ្ងៃទី .................. ខែ .................. ឆ្នាំ ២០ ........ ដើម្បីឱ្យលោក/លោកស្រីជាមេធាវី អាចត្រៀមរៀប ចំការពារកូនក្តីខ្លួនបាន ។

☐ យើងបានប្រាប់ដល់ជននេះ: អំពីសិទ្ធិទទួលបានជំនួយពីមេធាវី ដែលជននេះអាចជ្រើសរើសពីងដោយខ្លួនឯង ឬអាចសុំឱ្យគេចាត់តាំងមេធាវីណាម្នាក់ឱ្យខ្លួនបាន ។

☐ យើងបានប្រាប់ផងដែរដល់ជននេះថា: ប្រសិនបើមិនធ្វើការជ្រើសរើស ឬពឹងមេធាវី ដោយខ្លួនឯងទេ នោះមេធាវី ០១ រូប នឹងត្រូវបានចាត់តាំងដោយឯកឯង ដោយសារតែជន នេះជាអនីតិជន ។

ជននេះបានប្រកាសប្រាប់ថា:

☐ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ ខ្ញុំស្នើសុំឱ្យចាត់តាំងមេធាវី ០១ រូបឱ្យខ្ញុំ

☐ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា: គាត់មានសិទ្ធិអាចនៅស្ងៀម មិនផ្តល់ចម្លើយក៏បាន ឬអាចធ្វើសេចក្តីប្រកាសផ្សេងៗ ឬអាចឱ្យយើងសួរចម្លើយក៏បាន ។

ជននេះបានប្រកាសប្រាប់ថា: ..................................................

..................................................

..................................................

លោកមេធាវី .................................................. បានផ្តល់សេចក្តីកត់សំគាល់ការពារថា:

..................................................

..................................................

..................................................

☐ យើងបានជូនដំណឹងដល់ជននេះថា: យើងសម្រេចដាក់គាត់ឱ្យស្ថិតនៅក្រោមការត្រួត ពិនិត្យ:

☐ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឱ្យដឹង។

☐ ចំពោះតែអង្គហេតុដែលបានរៀបរាប់ខាងក្រោម ដែលយើង

បានបញ្ជាក់ប្រាប់:

☐ ជននេះ អំពីឈ្មោះនៃបទល្មើស: ..................................................

..................................................................................................

..................................................................................................

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការសុំឱ្យយើងធ្វើកិច្ចការស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្តឹងសុំមោឃភាពនៃកិច្ចស៊ើបសួរដោយផ្អែកទៅតាមមាត្រា ២៥៣ ប្តឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុងពេលដំណើរការនៃការស៊ើបសួរ ក្នុងលក្ខខ័ណ្ឌដែល មានចែងក្នុងមាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសំរាប់នីតិវិធីបន្ទាប់ មកទៀត ហើយប្រសិនបើមិនបានជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមិនមាន សំណើសុំ យើងនឹងធ្វើការចាត់តាំងមេធាវី ០១ រូបជូន(សម្រាប់តែក្នុងករណីដែលជនត្រូវចោទ មិនបានជ្រើសរើសឬពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំចាត់តាំងមេធាវីឱ្យ)។

☐ ជនត្រូវចោទបានប្រកាសថា:

- ☐ ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង
- ☐ ខ្ញុំស្នើសុំចាត់តាំងមេធាវី ០១ រូបឱ្យខ្ញុំ
- ☐ ខ្ញុំបដិសេធជំនួយពីមេធាវី

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា: គាត់អាចសុំបិទការស៊ើបសួរបាននៅពេលផុត រយៈពេល ០១ ឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា: នៅថ្ងៃនេះយើងសម្រេចឃុំខ្លួនគាត់ជាបណ្តោះ អាសន្នសិន ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា: នៅថ្ងៃនេះយើងសម្រេចដាក់គាត់ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងប្រាប់គាត់អំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវ គោរព ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា: យើងសំរេចមិនឃុំខ្លួនគាត់(ឱ្យនៅក្រៅឃុំ ) ។

☐ យើងបានប្រាប់ជនត្រូវចោទថា: គាត់ត្រូវប្រកាសប្រាប់អំពីអាសយដ្ឋាន ដែលអាចជាអាសយដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ ដែលទទួលបន្ទុកទទួលលិខិតដែលបញ្ជូនឱ្យគាត់ ប្រសិនបើគាត់អាចផ្តល់ឲ្យភ្លាមៗ នូវការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់តតិយជននោះ: អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ ត្រូវមានទីតាំងស្ថិតនៅ ..................................................

..................................................................................................

ជនត្រូវចោទ បានប្រកាសពីអាសយដ្ឋានដូចខាងក្រោម:

☐ ជាអាសយដ្ឋានផ្ទាល់ខ្លួន

☐ ជាអាសយដ្ឋានរបស់ ..............................................................................

..............................................................................................................

☐ យើងបានប្រាប់ដល់ជនត្រូវចោទបន្ថែមទៀតថា:

-រហូតដល់បិទការស៊ើបសួរ គាត់ត្រូវប្រាប់យើងនូវរាល់ការផ្លាស់ប្តូរអាសយដ្ឋានដែលបានប្រកាសប្រាប់ខាងលើ ដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិទ្ធិ ។

-គ្រប់ការជូនដំណឹងឬការឱ្យដំណឹងបញ្ជូនទៅអាសយដ្ឋាន ដែលបានប្រកាសប្រាប់ជា ចុងក្រោយបង្អស់ត្រូវចាត់ទុកថា: ជាការជូនដំណឹងដល់បុគ្គលជនត្រូវចោទហើយ ។

☐ យើងបានប្រាប់ដល់ជនត្រូវចោទ ឱ្យអានឡើងវិញនូវសេចក្តីប្រកាសរបស់ខ្លួនទាំងអស់ ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ បើមិនមានបដិសេធត្រង់ចំណុចណាទេ ឱ្យជននេះចុះហត្ថលេខាឬផ្តិតមេដៃលើកំណត់ហេតុនេះ ។

☐ បានអានឱ្យស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធត្រង់ចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

**ជនត្រូវចោទ** **មេធាវី** **អ្នកបកប្រែ** **ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
មន្ទីរស៊ើបសួរអក្សរ "ទ"
សំណុំរឿងលេខ
ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

## កំណត់ហេតុស្ដីពីការពិភាក្សាជេញជោលចំពោះមុខ

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ម្ភៃ ខែធ្នូ ថ្ងៃទីម្ភៃមួយ វេលាម៉ោង បួន និង ដប់ប្រាំ នាទីរសៀល
យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល
អមដោយលោក ជាក្រឡាបញ្ជី ។

-និងដោយមានវត្តមានលោក/លោកស្រី .................................................... ជាអ្នកបកប្រែ ។

-យោងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ .................. ដកសស/២០ ចុះថ្ងៃទី......... ខែ........... ឆ្នាំ២០២០។

បានមកបង្ហាញខ្លួន នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល និងនាមខ្លួនៈ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតសង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្នភូមិព្រែកឡេវ សង្កាត់ពរកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ ម្ដាយឈ្មោះ (ស) ប្រពន្ធឈ្មោះ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារចំនួន០២លើក ។

ជននេះបានប្រកាសប្រាប់ថាៈ ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ ឆ្នាំ ដែលស្ថិតនៅលំនៅឋានបច្ចុប្បន្ន ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការៈ ..........................................................................
..........................................................................................................

☐ ជននេះៈ ☑ ចេះនិយាយ ☑ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ
☐ ជននេះៈ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ពីបទៈ .......................................
..........................................................................................................
..........................................................................................................

អំពើដែលមានចែង និង ឱ្យផ្ដន្ទាទោសដោយមាត្រា ..........................................................
..........................................................................................................
..........................................................................................................

☐ យើងបានប្រាប់ថាៈ ជនត្រូវចោទអាចសុំពន្យាពេលដើម្បីរៀបចំការការពារខ្លួនបាន ។

☐ យើងក៏បានបញ្ជាក់ប្រាប់ជនត្រូវចោទផងដែរថា: យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃនេះ ។

☐ ជនត្រូវចោទ នៅមិនទាន់មានមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថា: ជនត្រូវចោទទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬពីងមេធាវីតាមការចាត់តាំង ។

☐ ជនត្រូវចោទបានប្រកាសប្រាប់ថា:

   ☐ ខ្ញុំបដិសេធជំនួយពីមេធាវី

   ☐ ខ្ញុំចង់បានជំនួយពីមេធាវី

លោក/លោកស្រីមេធាវី .................................... ត្រូវបានជូនដំណឹងដោយ .................................... អាចពិគ្រោះមើលសំណុំរឿងដែលទុក ឱ្យគាត់ពិនិត្យ និងអាចសន្ទនាបានដោយសេរីជាមួយកូនក្តីរបស់គាត់។

ការពិភាក្សាដេញដោលចំពោះមុខ ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន:

   ☐ ត្រូវបានធ្វើ

   ☐ ត្រូវបានលើកទៅថ្ងៃទី .......... ខែ .......... ឆ្នាំ ២០...... តាមសំណូមពររបស់ ..........................................................................។

តំណាងអយ្យការ បានបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម:

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

ជនត្រូវចោទ បានបង្ហាញសេចក្តីសង្កេតរបស់ខ្លួនដូចខាងក្រោម:

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

លោក/លោកស្រី .................................... បានបង្ហាញសេចក្តីសន្និដ្ឋានការពារកូនក្តីរបស់ខ្លួនដូចខាងក្រោម:

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

☐ យើងបានប្រាប់ដល់ជនត្រូវចោទថា: យើងសម្រេចចេញដីកាឱ្យឃុំខ្លួនបណ្តោះអាសន្នដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឱ្យឃុំខ្លួននៅថ្ងៃនេះ ។

☐ យើងបានឱ្យជនត្រូវចោទ អានឡើងវិញនូវសេចក្តីប្រកាសរបស់ខ្លួន ដែលយើងបានកត់ត្រាចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនមានបដិសេធត្រង់ចំណុចណាទេ ឱ្យចុះហត្ថលេខានៅលើកំណត់ហេតុនេះ ។

☐ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធត្រង់ចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើងនិងក្រឡាបញ្ជី ។

**ជនត្រូវចោទ** **មេធាវី** **ក្រឡាបញ្ជី** ***តំណាងអយ្យការ*** **ចៅក្រមស៊ើបសួរ**

***កំណត់សំគាល់:*** *កំណត់ហេតុនេះ ត្រូវធ្វើឡើងបន្តពីកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងធ្វើក្នុងថ្ងៃតែមួយ។*

ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

លេខ ៩៩៣៣ / ២០

## ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញ មាត្រា២០៣ ដល់មាត្រា២០៦ និងមាត្រាផ្សេងៗទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ស.ស ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៥៥៣ ដកសស ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ ដែលបានបើកការស៊ើបសួរលើឈ្មោះ ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតសង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្នភូមិព្រែកឡ្យូវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ ប្រពន្ធឈ្មោះ ជាតិតិជន ទោសពីមុខធ្លាប់ជាប់ពន្ធនាគារចំនួន០២លើក ។ (ឃាត់ខ្លួន២១.១២.២០)

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រែកឡ្យូវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង

-បានឃើញ កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ និងការកត់សម្គាល់របស់ភាគី។

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១.ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ ត្រូវចោទពីបទ៖ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិព្រែកឡ្យូវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

២.កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ៧ និង ១០ នាទីព្រឹក ឈ្មោះ បានយកកាំភ្លើងខ្លីម៉ាក Lock 98 លេខ ០០០៨០៩០៩២៣៦ ដែលខ្លួនបានទិញយកមកលាក់ទុកនៅក្នុងផ្ទះ យកមកបាញ់ទៅលើជនរងគ្រោះឈ្មោះ ត្រូវជាបងបង្កើតរបស់ខ្លួន ត្រូវចំក្រោមភ្លៀកខាងស្ដាំ ធ្លាយទៅដើមដៃខាងមុខ រងរបួសយ៉ាងធ្ងន់ធ្ងរ ដោយសារប្រច័ណ្ឌឈ្មោះ ជាមួយប្រពន្ធរបស់ខ្លួនឈ្មោះ ។ ហើយជនរងគ្រោះបានរត់គេច

ចេញ តែជនត្រូវចោទឈ្មោះ បានដេញតាមបាញ់បន្ថែមទៀត ប៉ុន្តែត្រូវបានឪពុកក្មេករបស់ខ្លួនចាប់ឃាត់ និងដណ្ដើមកាំភ្លើងបានពីជនត្រូវចោទ ហើយជនត្រូវចោទបានរត់គេចខ្លួនបាត់ ។ ក្រោយមកសមត្ថកិច្ចបានស្រាវជ្រាវចាប់ឃាត់ខ្លួនបានជនត្រូវចោទ និងកសាងសំណុំរឿងបញ្ជូនមកតុលាការតែម្ដង ។

៣.តំណាងអយ្យការបានស្នើឱ្យឃុំខ្លួនជនត្រូវចោទឈ្មោះ ជាបណ្ដោះអាសន្នតាមរយៈដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីបញ្ចប់បទល្មើស និងបង្ការបទល្មើសកុំឱ្យកើតជាថ្មី និងកាលៈទេសៈ នៃបទល្មើស ។

៤.ជនត្រូវចោទឈ្មោះ ធ្វើសេចក្ដីកំណត់សម្គាល់ថា ខ្លួនមិនជំទាស់នឹងការសម្រេចឃុំខ្លួនរបស់ចៅក្រមស៊ើបសួរទេ ។

II. សំអាងហេតុនៃសេចក្ដីសម្រេច

៥.ជនត្រូវចោទខាងលើត្រូវចោទពីបទឧក្រិដ្ឋ/មជ្ឈិម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ)ឆ្នាំ (មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

៦.ដើម្បីរក្សាកុំឱ្យមានការគាបសង្កត់លើសាក្សី និងធានាការពារសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានភាពច្របូកច្របល់ និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី ។ ដូច្នេះការឃុំខ្លួនបណ្ដោះអាសន្នមានសារសំខាន់ដើម្បីធានាក្នុងការស្រាវជ្រាវ និងការស៊ើបសួរ ព្រមទាំងការស្ដាប់ចម្លើយសាក្សីនានា ។ ម្យ៉ាងទៀតដោយសារវិធានការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលតម្រូវឱ្យបំពេញកាតព្វកិច្ចនីមួយៗនោះមានលក្ខណៈមិនទាន់តឹងរឹង និងគ្មានប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះ ។ ដូច្នេះ មានតែការឃុំខ្លួនបណ្ដោះអាសន្នដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ និងគប្បីកំណត់រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងរយៈពេល ០៦ (បួន) ខែ ក្នុងពន្ធនាគារខេត្តកណ្ដាល ។

ហេតុដូច្នេះ សម្រេច

ឃុំខ្លួនជនត្រូវចោទឈ្មោះ ភេទប្រុស (អត្តសញ្ញាណដូចខាងលើ) ជាបណ្ដោះអាសន្នរយៈពេលអតិបរមា ហើយយើងនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដើម្បីអនុវត្តការឃុំខ្លួននេះ។

ថ្ងៃចន្ទ ៧កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅខេត្តកណ្ដាល ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរ

ឧបសម្ព័ន្ធទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

~~**†**~~

**សាលាដំបូងខេត្តកណ្ដាល**

មន្ទីរស៊ើបសួរ (ទ)

សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី......ខែ.........ឆ្នាំ ២០២០

លេខ 4934 ដកបឃខ

## ដីកាបង្គាប់ឲ្យឃុំខ្លួន

យើង ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** មាត្រា ២១៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** មាត្រា ២០៣ ,មាត្រា២០៤ មាត្រា ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ. ថ្ងៃទី.. .ខែ.. ...ឆ្នាំ២០២០។

-**បានឃើញ** សំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ.. ........ភេទ ប្រុស ...អាយុ 35 ឆ្នាំសញ្ជាតិ ខ្មែរ មុខរបរ [illegible] ទីកន្លែងកំណើតនៅភូមិ............ ឃុំ/សង្កាត់ [illegible] ស្រុក/ក្រុង [illegible] ខេត្ត/រាជធានី ភ្នំពេញ...... និងទីលំនៅបច្ចុប្បន្ននៅភូមិ [illegible] ឃុំ/សង្កាត់ [illegible] ស្រុក/ក្រុង...... តាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ... ......(ស)ម្ដាយឈ្មោះ.. ..... (.ស.)ប្រពន្ធឬប្ដីឈ្មោះ...... ..................ទោសពីមុន [illegible] ។

ជននេះត្រូវចោទពីបទ៖ [illegible] ប្រព្រឹត្តនៅភូមិ [illegible] ឃុំ/សង្កាត់ [illegible] ស្រុក/ក្រុង តាខ្មៅ ខេត្ត/រាជធានី កណ្ដាល ...........កាលពីថ្ងៃទី 19 ខែ ធ្នូ ........ឆ្នាំ២០២០។បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា [illegible] ។

ឃាត់ខ្លួននៅថ្ងៃទី 20 ខែ ធ្នូ ........ ឆ្នាំ២០២០ ។

**បានឃើញ** ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ 4933 ចុះថ្ងៃទី 21 ខែ ធ្នូ .....ឆ្នាំ២០២០។

## សម្រេច

១.ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ..........ភេទ ប្រុស (*អត្តសញ្ញាណដូចខាងលើ*) ទៅពន្ធនាគារខេត្តកណ្ដាលដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់។

២.ឱ្យប្រធានពន្ធនាគារខេត្តកណ្ដាលទទួល និង ឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

៣.ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់ សហការអនុវត្តឲ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃ ច័ន្ទ ៧កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្ដាល ថ្ងៃទី 21 ខែ ធ្នូ ...... ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំដោះលែងឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន

ខ្ញុំបាទឈ្មោះ              កែវប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបើកបរឡាន មានទីលំនៅសព្វថ្ងៃនៅ ភូមិថ្មី ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

**សូមគោរពចូលមក**

**លោកចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ**

សូមមេត្តាជ្រាប:

**កម្មវត្ថុ:** សំណើសុំដោះលែងឲ្យបាននៅក្រៅឃុំជាបណ្ដោះអាសន្ន ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជូនលោកចៅក្រមមេត្តាជ្រាបថា: ខ្ញុំបាទត្រូវបានសាលាដំបូងឃុំខ្លួន កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្ដាលឲ្យរបួសអ្នកដទៃ ប្រព្រឹត្តនៅចំណុចភូមិស្រែមាន់ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៩ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ។

ខ្ញុំបាទ/នាងខ្ញុំស្នើសុំលោកចៅក្រម មេត្តាដោះលែងរូបខ្ញុំបាទឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ដើម្បីបានត្រឡប់ទៅផ្ទះវិញ ព្រោះសព្វថ្ងៃនេះក្រុមគ្រួសាររបស់ខ្ញុំបាទ ជួបការលំបាកខាងជីវភាពខ្លាំងណាស់ ដោយគ្មានអ្នកជួយប្រកបមុខរបររកស៊ីដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ។ ហេតុដូចនេះ ខ្ញុំបាទសូមអនុញ្ញាតពីលោកចៅក្រមទទួលបន្ទុករឿងក្ដី ដើម្បីឲ្យខ្ញុំបាទ/នាងខ្ញុំ បាននៅក្រៅឃុំបណ្ដោះអាសន្ន ហើយខ្ញុំសូមសន្យាថា ៖

- មិនរត់គេចវេសពីមូលដ្ឋាន
- មិនបង្កការរំខានដល់ការស៊ើបសួររបស់សាលាដំបូង
- មិនទៅគំរាមសាក្សី ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី
- សន្យាថានឹងមកបង្ហាញមុខចំពោះសាលាដំបូងរហូត នៅពេលមានដីកាកោះហៅ
- សន្យាថានឹងទទួលខុសត្រូវចំពោះមុខច្បាប់ ពេលសាលាដំបូងបានរកឃើញថា ខ្ញុំបាទ/នាងខ្ញុំមានកំហុស ។

អាស្រ័យដូចបានគោរពជម្រាបជូនតាមកម្មវត្ថុខាងលើ សូមលោកចៅក្រមមេត្តាអនុញ្ញាតឲ្យខ្ញុំបាទបាននៅក្រៅឃុំបណ្ដោះអាសន្នដោយក្ដីអនុគ្រោះ ។

សូមលោកចៅក្រម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ថ្ងៃពុធ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

កំពង់ស្ពឺ.ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១

បានឃើញ និងបញ្ជាក់ថា

ស្នាមមេដៃស្ដាំនេះពិតជារបស់ឈ្មោះ

**នេអាគ នី** ដែលកំពុងជាប់ឃុំខ្លួនក្នុងពន្ធនាគារ ខេត្តកំពង់ស្ពឺ ពិតប្រាកដមែន ។

ថ្ងៃពុធ ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

កំពង់ស្ពឺ.ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១

**ប្រធានពន្ធនាគារ**

ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
មន្ទីរស៊ើបសួរ "ខ"

លេខ .. .... /២១

## ដីកាបញ្ជូនឱ្យឆ្លើយ

យើង អនុប្រធាន និងជាចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៩ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ពាក្យសុំដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ របស់ជនត្រូវចោទឈ្មោះ ។

បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ទាក់ទិននឹងករណី បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្ដាលឱ្យរបួសអ្នកដទៃ ប្រព្រឹត្តនៅភូមិស្រែមាន់ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ទៅ តំណាងអយ្យការ ដើម្បីផ្ដល់យោបល់អំពី ពាក្យសុំដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន ។

ថ្ងៃ.[illegible]. ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កំពង់ស្ពឺ ថ្ងៃទី[illegible] ខែឧសភា ឆ្នាំ២០២១

ចៅក្រមស៊ើបសួរ

បានទទួលអនុវត្ត

ក្រឡាបញ្ជី

## យោបល់របស់តំណាងអយ្យការ

យើង ... ........ ព្រះរាជអាជ្ញា[illegible] នៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយខាងលើ ។

-បានឃើញ សំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ ....[illegible]....................................។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្នើសុំ ៖

☐....[illegible]....................................................

....................................................................................................

...................................................................................................។

ថ្ងៃ.[illegible].. ខែ.[illegible].. ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កំពង់ស្ពឺ, ថ្ងៃទី .[illegible]. ខែ.[illegible].. ឆ្នាំ២០២១

តំណាងអយ្យការ

ឧបសម្ព័ន្ធទី១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
មន្ទីរស៊ើបសួរ "ខ"
លេខ ..' ......./២១

## ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

យើង អនុប្រធាន និងជាចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ
អមដោយ ជាក្រឡាបញ្ជី

-បានឃើញ មាត្រា ២១៥ មាត្រា ២១៦ មាត្រា ២១៧ និងមាត្រា ២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣១២៨ អ.យ/២១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ២១៩ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២២៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ។

-បានឃើញ យោបល់របស់តំណាងអយ្យការ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ។

### ក្រោយពីបានពិនិត្យពិចារណាលើសំណុំរឿងចប់សព្វគ្រប់ហើយ
### យល់ឃើញថា

-បទល្មើសដែលចោទប្រកាន់ជាបទល្មើសមធ្យម ។

-ជនត្រូវចោទមានទីលំនៅច្បាស់លាស់ ហើយសន្យាថានឹងបង្ហាញខ្លួនគ្រប់ពេល ដែលមានដីកាកោះហៅ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលសំណង និងយល់ព្រមដកពាក្យបណ្ដឹង។

-ការស៊ើបសួរមានភាពជឿនលឿន ការសម្រេចឱ្យជនត្រូវចោទនៅក្រៅឃុំមិនធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរទេ ។

### ហេតុដូច្នេះសម្រេច

-អនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិថ្មី ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន០២នាក់ ទោសពីមុនគ្មាន។

ដែលត្រូវចោទប្រកាន់ពីបទ បើកបរដោយធ្វេសប្រហែស ធ្លោយ មិនប្រុងប្រយ័ត្ន បណ្តាលឲ្យរបួសអ្នកដទៃ ប្រព្រឹត្តនៅភូមិស្រែមាន់ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក *ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន* ។

ថ្ងៃ..........ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ ថ្ងៃទី ...21.... ខែឧសភា ឆ្នាំ២០២១

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ
ថ្ងៃ.............. ខែ.......... ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ ថ្ងៃទី..២១.. ខែ..ឧសភា.. ឆ្នាំ២០២១
**តំណាងអយ្យការ**

ឧបសម្ព័ន្ធទ១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
មន្ទីរស៊ើបសួរ "ខ"
លេខ ....... ......./២១

## ដីកាបង្គាប់ឱ្យដោះលែង

យើង អនុប្រធាន និងជាចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៩ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ២១៩ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៩២៤ អ.យ/២១ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ. ..../២១ ចុះថ្ងៃទី.២១ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ ។

## បង្គាប់

ឱ្យប្រធានពន្ធនាគារខេត្តកំពង់ស្ពឺ ដោះលែងជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិថ្មី ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ ម្ដាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន០២នាក់ ទោសពីមុនគ្មាន។

ត្រូវចោទពីបទ បើកបរដោយធ្វេសប្រហែស ឬខ្វះការប្រុងប្រយ័ត្ន បណ្ដាលឱ្យរបួសអ្នកដទៃ ប្រព្រឹត្តនៅភូមិស្រែមាន់ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

ថ្ងៃ.សុក្រ.១០កើត... ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ, ថ្ងៃទី.២១..... ខែឧសភា ឆ្នាំ២០២១
**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ
ថ្ងៃ..សុក្រ.១០កើត. ខែ.ពិសាខ.. ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ, ថ្ងៃទី..២១.. ខែ..ឧសភា... ឆ្នាំ២០២១
**តំណាងអយ្យការ**

ឧបសម្ព័ន្ធទ១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
មន្ទីរស៊ើបសួរ
លេខ .5552......./២១

# ដីកាសម្រេច

## ដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង អនុប្រធាន និងជាចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ

អមដោយលោក ជាក្រឡាបញ្ជី

-បានឃើញ មាត្រា ២២៣ មាត្រា ២២៦ មាត្រា ២៣០ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៩ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ២១៩ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៩២៤ អ.យ/២១ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១។

-បានឃើញ ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ ..5551......... /២១ ចុះថ្ងៃទី..21 ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

## យ ល់ ឃើ ញ ថា

ដើម្បីធានាវត្តមានជនត្រូវចោទចំពោះមុខតុលាការ និងដើម្បីជៀសវាងការរាំងស្ទះក្នុងដំណើរការនៃនីតិវិធី គប្បីសម្រេចដាក់ជនត្រូវចោទឲ្យជាប់កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ។

## ហេ តុ ដូ ច្នេះ ស ម្រេ ច

១/.ដាក់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិថ្មី ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ ម្ដាយឈ្មោះ "ស" ប្រពន្ធឈ្មោះ ធួក ធីតា មានកូន០២នាក់ ទោសពីមុខគ្មាន។

ដែលត្រូវចោទប្រកាន់ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្ដាលឲ្យរបួសអ្នកដទៃ ប្រព្រឹត្តនៅភូមិស្រែមាន់ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៨៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

ឲ្យគោរពកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការដូចខាងក្រោម៖

ក.ត្រូវចូលទៅបង្ហាញខ្លួននៅប៉ុស្តិ៍នគរបាលរដ្ឋបាលតាំងក្រសាំង រៀងរាល់មួយខែម្ដង នៅថ្ងៃទី០១ ដល់ ថ្ងៃទី០៥ នៃខែនីមួយៗ។

ខ.មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

គ.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គល ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

២/.ក្នុងករណីដែលជនត្រូវចោទគេចវេសដោយចេតនាមិនអនុវត្តតាមចំណុចខាងលើ ចៅក្រមស៊ើបសួរនឹងចាប់ឃុំខ្លួនជនត្រូវចោទឡើងវិញ ដោយអនុវត្តតាមមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣/.ដីកានេះមានប្រសិទ្ធិភាពអនុវត្តភ្លាម។

ថ្ងៃ.............ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កំពង់ស្ពឺ, ថ្ងៃទី....២១...ខែឧសភា ឆ្នាំ២០២១

ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរ

បានទទួលដំណឹងរួចហើយ

ថ្ងៃ.............ខែ..........ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កំពង់ស្ពឺ, ថ្ងៃទី..២២...ខែ..ឧសភា.. ឆ្នាំ២០២១

តំណាងអយ្យការ

ឧបសម្ព័ន្ធទ១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
មន្ទីរស៊ើបសួរ
លេខ.... .../២១

## ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង ចៅក្រមស៊ើបសួរ និងជាអនុប្រធាននៃសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ មាត្រា ១៩៥ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤៣២ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៨៧ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌស៊ើបសួរលេខ ៣២៥៦ អ.យ/២១ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២១ ដែលមានជនត្រូវចោទឈ្មោះ ហៅ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិក្រញូង ឃុំពោធិ៍អង្រ្កង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ នៅលើរ។

ដែលចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅភូមិព្រៃកញ្ឆាន់ ឃុំភារីមានជ័យ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៥៣ មាត្រា ៣៥៧ មាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

## យល់ឃើញថា

-ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងក្រោយពេលប្រព្រឹត្តបទល្មើសបានគេចខ្លួន និងមានសាវតាជាតិគ្រប់គ្រាន់ ។

-ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឲ្យចូលខ្លួន និងនាំខ្លួន ប៉ុន្តែមិនទទួលបានលទ្ធផលនោះទេ ។

-គប្បីចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនត្រូវចោទឈ្មោះ ហៅ ភេទប្រុស អាយុ២៤ឆ្នាំ ។

## ហេតុដូច្នេះសម្រេច

បញ្ជាដល់មន្ត្រីនគរបាលយុត្តិធម៌ និងកងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរក ចាប់ខ្លួន និងនាំខ្លួនជនត្រូវចោទឈ្មោះ (សាវតាជាតិដូចខាងលើ) មកប្រគល់ឲ្យជូនសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីចាត់ការតាមនីតិវិធី ។

ថ្ងៃ.[illegible].. ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ ថ្ងៃទី .២១... ខែកក្កដា ឆ្នាំ២០២១
ចៅក្រមស៊ើបសួរ

ឧបសម្ព័ន្ធទ១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
មន្ទីរស៊ើបសួរ

លេខ ............/២១

## ដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន

យើង អនុប្រធាន និងជាចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ

អមដោយលោក ជាក្រឡាបញ្ជី

-បានឃើញ មាត្រា ២១១ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣១៧ អ.យ/២១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ២០ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ដែលមានជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់បាយ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "រ" ប្រពន្ធឈ្មោះ មានកូន១នាក់ កម្រិតវប្បធម៌ថ្នាក់ទី៧ ទោសពីមុន៖ ជាបពន្ធនាគារ១ខែពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ត្រូវចោទពីបទៈ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៦ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ។

### សំអាងហេតុ

កិច្ចស៊ើបសួរមិនទាន់បានបំពេញសព្វគ្រប់ជ្រៅជ្រះ ហេតុនេះការពន្យារពេលឃុំខ្លួនបណ្ដោះអាសន្នជាវិធានចាំបាច់ក្នុងការធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

### ហេតុដូច្នេះសម្រេច

ពន្យារពេលឃុំខ្លួនជនត្រូវចោទឈ្មោះ (មានអត្តសញ្ញាណដូចខាងលើ) ជាបណ្ដោះអាសន្ន ហើយយើងនឹងបង្គាប់ឱ្យឃុំខ្លួនជននេះតាមអំណាចដីកាបង្គាប់ឱ្យពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន ។

ថ្ងៃ............ ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ ថ្ងៃទី...... ខែឧសភា ឆ្នាំ២០២១

ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរ

បានទទួលដំណឹងហើយ
ថ្ងៃ............ ខែ............ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ, ចុះថ្ងៃទី០៤ ខែ...... ឆ្នាំ២០២១
តំណាងអយ្យការ

ឧបសម្ព័ន្ធទ១៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកំពង់ស្ពឺ

មន្ទីរស៊ើបសួរ

លេខ .          ... /២១

## ដីកាបង្គាប់ឲ្យពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន

យើង          អនុប្រធាន និងជាក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ មាត្រា ២១១ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៧ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣១៧ អ.យ/២១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ២០ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្ដោះអាសន្នលេខ...4806.......... ចុះថ្ងៃទី..03..... ខែឧសភា ឆ្នាំ២០២១។

ជនត្រូវចោទឈ្មោះ          ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់បាយ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ          "រ" ម្ដាយឈ្មោះ          "រ" ប្រពន្ធឈ្មោះ ផាត់ ផានី មានកូន១នាក់ កម្រិតវប្បធម៌ថ្នាក់ទី៧ ទោសពីមុខ៖ ជាប់ពន្ធនាគារ១ខែពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

ត្រូវចោទពីបទៈ រក្សាទុក ដឹកជញ្ជូន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**បង្គាប់**

ឲ្យប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនខេត្តកំពង់ស្ពឺ ពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នលើជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

ថ្ងៃ...ទី១...ខែ២០២៥..... ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កំពង់ស្ពឺ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ

លេខ .. /២១

## ដីកាបង្គាប់ឲ្យកោះហៅ
## ជនត្រូវចោទនៅក្នុងឃុំជាបណ្ដោះអាសន្ន

(មាត្រា ២៤៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

យើង ចៅក្រមស៊ើបសួរ និងជាអនុប្រធាននៃសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦៦ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៦៥៣ ដស.បស/២០ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទឈ្មោះ លេខ ៧៦៧/២១ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទឈ្មោះ លេខ ៤៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៦៨ អ.យ/២១ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ ។

-បានឃើញ ដីកាដំណោះស្រាយលេខ....1129.........ដកដស/២១ ចុះថ្ងៃទី.២២.. ខែមិថុនា ឆ្នាំ២០២១ ដែលបានសម្រេចចោទប្រកាន់លើឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំធ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "រ" នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី៧ថ្មី ទោសពីមុនគ្មាន។

ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាំងតាឡាត់ ឃុំធ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ តាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

### ហេតុដូច្នេះ

-បង្គាប់មកប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនខេត្តកំពង់ស្ពឺ ឲ្យរក្សាឈ្មោះ (មានអត្តសញ្ញាណខាងលើ) ឲ្យនៅជាប់ឃុំបណ្ដោះអាសន្នរហូតដល់មានសេចក្ដីបង្គាប់ផ្សេងពីនេះ។

ថ្ងៃ.[illegible]. ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កំពង់ស្ពឺ ថ្ងៃទី..២២..ខែមិថុនា ឆ្នាំ២០២១
ចៅក្រមស៊ើបសួរ

ឧបសម្ព័ន្ធទ១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
មន្ទីរស៊ើបសួរ "ខ"
លេខ....៤២១..... ដកឋស/២១

## ដី កា ដំ ណោះ ស្រា យ
( ប ញ្ជូ ន ទៅ ជំ នុំ ជ ម្រះ )

យើង ចៅក្រមស៊ើបសួរ និងជាអនុប្រធាននៃសាលាដំបូងខេត្តកំពង់ស្ពឺ

អមដោយលោក : ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ស្ពឺ

-បានឃើញ មាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មបញ្ញត្តិមាត្រា ២៤៧, មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម//០៦១៣/០០៩ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦៦ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៦៥៣ ដស.បស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៤៩ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥៤៦៨ ដកសព ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញ ឯកសារនានាពាក់ព័ន្ធក្នុងសំណុំរឿង។

### ក្រោយពីបានពិនិត្យសំណុំរឿង និងស៊ើបសួរចប់សព្វគ្រប់អស់ហើយ

***មានពិរុទ្ធភាពគ្រប់គ្រាន់លើ***

១-ឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំផ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ម្ដាយឈ្មោះ នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី៧ថ្មី ទោសពីមុនគ្មាន។ (ក្នុងឃុំ)

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាំងតាឡាត់ ឃុំផ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ តាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឈ្មោះ ហៅ ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំផ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ម្ដាយឈ្មោះ "រ" ប្រពន្ធឈ្មោះ "រ" មានកូន០២នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ថ្មី ។ (គេចខ្លួន)

៣-ឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ថ្មី ។ (គេចខ្លួន)

៤-ឈ្មោះ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី៥ថ្មី ។ (គេចខ្លួន)

៥-ឈ្មោះ ហៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន០៤នាក់ កម្រិតវប្បធម៌ថ្នាក់ទី៥ថ្មី ។ (គេចខ្លួន)

៦-ឈ្មោះ ហៅ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន០១នាក់ ។ (គេចខ្លួន)

៧-ឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិត្នោតជ្រុំ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ម្តាយឈ្មោះ "រ" នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី៣ ទោសពីមុខ ធ្លាប់ជាប់ពន្ធនាគារខេត្តកំពង់ស្ពឺរយៈពេល៥ឆ្នាំ ពាក់ព័ន្ធនឹងបទល្មើសប្លន់ (ចេញពីពន្ធនាគារកាលពីខែកក្កដា ឆ្នាំ២០០៨) ។ (ក្នុងឃុំ)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាំងតាឡាត់ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ និងកាលពីអំឡុងដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០១ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

***អង្គហេតុនៃរឿងក្តីមានដូចតទៅ៖***

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ វេលាម៉ោង១១ និង១០នាទី ស្ថិតនៅចំណុចភូមិតាំងតាឡាត់ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កម្លាំងអធិការដ្ឋាននគរបាលស្រុកសំរោងទង បានធ្វើការបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយឃាត់ខ្លួនបានជនសង្ស័យឈ្មោះ ដកហូតបានគ្រឿងញៀនប្រភេទម៉ាទឹកកកចំនួន ៤១(សែសិបមួយ)កញ្ចប់ ទម្ងន់ ១៣,១២ក្រាម។

## សំអាងហេតុ

១-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅដំណាក់កាលនៅក្រុមស៊ើបសួរថា៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលអយ្យការទុកនៅដដែល ដោយបន្ថែមនូវអ្នកដែលពាក់ព័ន្ធក្នុងរឿងនេះម្នាក់ដែលមានឈ្មោះ ភេទប្រុស អាយុប្រហែល២៥ឆ្នាំ រស់នៅភូមិត្រពាំងមាន់ ឃុំថ្លាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដោយសារតែថ្ងៃកើតហេតុនោះឈ្មោះ នេះ ក៏បានជិះម៉ូតូទៅជាមួយខ្លួនដែរ ហើយគាត់ជាដៃគូរបស់ឈ្មោះ ហើយខ្លួនដឹងថាកន្លងមកឈ្មោះ ជាអ្នកលក់ថ្នាំញៀន

33/6

ឲ្យឈ្មោះ ។ ខ្ញុំបាទសូមជម្រាបជូនតុលាការថា កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ស្ថិតនៅភូមិតាំងតាឡាត់ ឃុំច្បាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ខ្ញុំបាទយកថ្នាំញៀនដែលឈ្មោះ បានឲ្យខ្ញុំបាទយកទៅឈរលក់ចំនួន ៤១កញ្ចប់តូច ដោយថ្នាំញៀននោះ គឺលក់ក្នុងតម្លៃ ២ម៉ឺនរៀល ក្នុង១កញ្ចប់។ មុនពេលកើតហេតុនោះគឺខ្ញុំបាទត្រូវបានឈ្មោះ ! និងឈ្មោះ បានជិះម៉ូតូមកយកខ្ញុំបាទនៅផ្ទះ ហើយប្រាប់ថាទៅនោះជាមួយខ្ញុំបាទមួយភ្លែត។ នៅពេលដែលដល់ទីតាំងហើយឈ្មោះ ឲ្យលុយខ្ញុំបាទចំនួន២ម៉ឺនរៀល និងបានហុចថ្នាំញៀនចំនួន ៤១កញ្ចប់ ដែលដាក់នៅក្នុងកាបូបពណ៌ប្រផេះមកឲ្យខ្ញុំបាទ ដោយខ្ញុំបាទដឹងថាគាត់ឲ្យថ្នាំញៀនមកនេះគឺដើម្បីយកលក់ទៅឲ្យគេ។ បន្តិចក្រោយមកឈ្មោះ និងឈ្មោះ ក៏បានជិះម៉ូតូចេញបាត់ទៅ លុះក្រោយមកក៏មានសមត្ថកិច្ចមកធ្វើការឆែកឆេរខ្លួនខ្ញុំបាទ ក៏ឃើញមានថ្នាំញៀនទាំង ៤១កញ្ចប់នោះ ហើយក៏បានឃាត់ខ្លួនខ្ញុំបាទតែម្តងទៅ។ ខ្ញុំបាទចេះប្រើប្រាស់ថ្នាំញៀនចំនួន១ឆ្នាំហើយ និងប្រើប្រាស់បានច្រើនលើកផងដែរ។ ថ្នាំញៀនដែលខ្ញុំបាទទិញមកប្រើប្រាស់នេះ គឺខ្ញុំបាទទិញពីឈ្មោះ ដែលអ្នកទាំងនេះ គឺរស់នៅភូមិត្នោតជ្រុំ ឃុំច្បាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ សមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទនៅថ្ងៃទី១២ ខែមករា ឆ្នាំ ២០២១ ដោយដកហូតលុយពីខ្ញុំបាទប្រហែលខ្ទង់ ១០ម៉ឺនរៀល។ ខ្ញុំបាទសំណូមពរឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្ញុំបាទផង។

២-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅជំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្ញុំបាទជាប់ឃុំក្នុងពន្ធនាគារខេត្តកំពង់ស្ពឺ ដោយសារតែពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។ នៅក្នុងសំណុំរឿងនេះ គឺខ្ញុំបាទបានដឹងអំពីបទល្មើសដែលគេចោទប្រកាន់មកលើខ្ញុំបាទហើយ ហើយកន្លងមកខ្ញុំបាទពិតជាធ្លាប់ជួញដូរគ្រឿងញៀនពិតប្រាកដមែន។ ដោយឡែកឈ្មោះ ព្រោះវារស់នៅភូមិជាមួយគ្នា ដោយកន្លងមកខ្ញុំបាទក៏ធ្លាប់ប្រើឲ្យវាយកថ្នាំឲ្យគេម្តងម្កាលដែរ ដោយបន្ទាប់ពីពេលដែលវាយកទៅឲ្យគេហើយ ខ្ញុំបាទឲ្យលុយវា ២ម៉ឺន ទៅ៣ម៉ឺនរៀល។ ខ្ញុំបាទចេះប្រើប្រាស់ថ្នាំញៀនរយៈពេលជិត២ឆ្នាំហើយ និងចេះលក់បានប្រហែលជាង១ខែ ក៏ត្រូវសមត្ថកិច្ចចាប់ខ្ញុំបាទតែម្តងទៅ។ ! ព្រោះនៅភូមិជាមួយគ្នា និងចេះប្រើប្រាស់គ្រឿងញៀនទៀតផង។ ខ្ញុំបាទសំណូមពរឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសឲ្យខ្ញុំបាទផង។

៣-តាមពាក្យរបាយការណ៍របស់សមត្ថកិច្ច ចម្លើយរបស់ជនត្រូវចោទ និងភស្តុតាងនានានៅក្នុងសំណុំរឿងពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ; ភេទប្រុស កើតឆ្នាំ២០០៤ ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាំងតាឡាត់ ឃុំច្បាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ តាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ; ភេទប្រុស កើតឆ្នាំ១៩៨៦, ឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ, ឈ្មោះ ភេទប្រុស អាយុ៣១ឆ្នាំ ,ឈ្មោះ ហៅ ; ភេទប្រុស អាយុ៣៨ឆ្នាំ , ឈ្មោះ ហៅ តូច ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាំងតាឡាត់ ឃុំច្បាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាល

ពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ និងកាលពីអំឡុងដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០១ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ប្រាកដមែន។

៤-អំពើរបស់ជនត្រូវចោទបានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយរបស់សង្គម ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ ។

៥-ជនត្រូវចោទឈ្មោះ ឈ្មោះ . ឈ្មោះ ។ ហៅ ភ័ក្រ និងឈ្មោះ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យចូលខ្លួន និងដីកាបង្គាប់ឱ្យនាំខ្លួនជននេះមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ប៉ុន្តែនៅតែមិនទទួលបានលទ្ធផល ហេតុនេះចៅក្រមស៊ើបសួរសម្រេចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៨១/២១, ៣៨២/២១, ៣៨៣/២១ និង ៣៨៤/២១ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ និងលេខ ៤១០/២១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ដើម្បីបញ្ជាដល់មន្ត្រីនគរបាលយុត្តិធម៌ និងកងកម្លាំងសារធារណៈឱ្យស្រាវជ្រាវ ចាប់ខ្លួន និងនាំខ្លួនជនត្រូវចោទទាំងប្រាំនាក់ខាងលើ មកប្រគល់ជូនសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីចាត់ការតាមនីតិវិធី។

៦-ជាការចាំបាច់ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីត្រូវរក្សាជនត្រូវចោទឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ និងឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ ឱ្យនៅក្នុងឃុំជាបណ្តោះអាសន្នយោងតាមមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## <u>ហេតុដូច្នេះ សម្រេច</u>

ក.បញ្ជូនជនត្រូវចោទ៖

១-ឈ្មោះ ភេទប្រុស កើតឆ្នាំ២០០៤ ជនជាតិខ្មែរ។ (ក្នុងឃុំ)

***<u>ទៅជំនុំជម្រះ</u>*** ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាំងតាឡាត់ ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ តាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឈ្មោះ ហៅ ភេទប្រុស កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ។ (គេចខ្លួន)

៣-ឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ។ (គេចខ្លួន)

៤-ឈ្មោះ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ។ (គេចខ្លួន)

៥-ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ។ (គេចខ្លួន)

៦-ឈ្មោះ ហៅ ។ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ។ (គេចខ្លួន)

៧-ឈ្មោះ ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ។ (ក្នុងឃុំ)

***<u>ទៅជំនុំជម្រះ</u>*** ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាំងតាឡាត់ ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ និងកាលពីអំឡុងដើមខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០១ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ និងវត្ថុតាងនានាដែលពាក់ព័ន្ធក្នុងសំណុំរឿងនេះ ***<u>ទៅជំនុំជម្រះ</u>*** ។

គ.រក្សាជនត្រូវចោទឈ្មោះ ឲ្យនៅក្នុងឃុំជាបណ្ដោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួនមុខតុលាការជំនុំជម្រះ។

ថ្ងៃ.................... ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កំពង់ស្ពឺ, ថ្ងៃទី...... ខែមិថុនា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

**ក្រឡាបញ្ជី**

**បានទទួលដំណឹងរួចហើយ**

ថ្ងៃ..............................ខែ.............................. ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កំពង់ស្ពឺ, ថ្ងៃទី២៣ ខែ មិថុនា... ឆ្នាំ២០២១

**តំណាងអយ្យការ**